ក          N°28/16→*15/4/2016*

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៥៧ ស្តីពី ការបញ្ចប់មុខតំណែង តែងតាំង និង ផ្តល់ឋានៈឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ **គុយ ប៊ុនសន** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ៣១៧៧ |
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៥៨ ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងមុខតំណែង ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ **ចាន់ គឹមសេង** ជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ពន្ធនាគារ ក្រសួងមហាផ្ទៃ | ៣១៧៨ |
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៤៩ រូប | ៣១៧៩ |
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៦០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **និតជឺ អ៊ែប ហ្វ្រែនស៊ីស្កុស** (SCHNITGER ARP FRANCISCUS) ជនជាតិហូឡង់ សញ្ជាតិហូឡង់ | ៣១៨១ |
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៦១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **អ៊ូ ជីនជួង** (WU JINZHUANG) ជនជាតិចិន សញ្ជាតិចិន | ៣១៨២ |
| ៣១-៣-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/៣៦២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ០៥ រូប | ៣១៨៣ |
| ០១-៤-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មហាកណ្ឋាភរណ៍ឯករាជជាតិ ព្រះរាជាណាចក្រកម្ពុជា ចំពោះ សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) | ៣១៨៤ |
| ០១-៤-២០១៦ | -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៤ ស្តីពី ការដាក់ជូន ឯកឧត្តម **គុយ សុផល** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង | ៣១៨៥ |

០១-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **អ៊ុក ឆាវី** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៣១៨៦

០១-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **មូហាម៉ាត់ស៊េន មូសា** (MOHAMAD ZAIN MUSA) ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៣១៨៧

០១-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ និងលោកស្រី ចំនួន ០២ រូប ៣១៨៨

០៤-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៨ ស្តីពី ការបញ្ចប់មុខងារ និងតែងតាំងឯកឧត្តម ចំនួន ២៨ រូប ៣១៨៩

០៤-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៩ ស្តីពី ការបញ្ចប់មុខតំណែង និងតែងតាំងឯកឧត្តម ចំនួន ០២ រូប ៣១៩១

០៤-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧០ ស្តីពី ការតែងតាំងលោកជំទាវ **សូ ស្រីម៉ិច** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ៣១៩២

០៤-៤-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៧១ ស្តីពី ការតែងតាំងឯកឧត្តម **ឃឹម សិរីវឌ្ឍ** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ៣១៩៣


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


០១-៤-២០១៦ -អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣១៩៤

០១-៤-២០១៦ -អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣១៩៦

០១-៤-២០១៦ -អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពី ការកែសម្រួល និងការដំឡើងប្រាក់បំណាច់មុខងារ ជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ៣១៩៨

០៥-៤-២០១៦ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៣២០២

២៥-៣-២០១៦ -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣២២០

២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣២២១
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២២៤
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៣២
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣២៣៣
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣២៣៤
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៣៦
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣២៣៧
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៣៨
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣២៣៩
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៤១
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៤៣
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៤៤
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣២៤៦
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៤៨
២៨-៣-២០១៦ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣២៤៩

## ២_សារាចរណែនាំ

០៧-៤-២០១៦ -សារាចរណែនាំលេខ ០១ សរណន ស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧ ៣២៥០

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-០២-២០១៦ -ប្រកាសលេខ ១៦១ សហវ.ប្រក ស្តីពី ការកែសម្រួលការិយាល័យមួយចំនួន ក្រោមឱវាទនាយកដ្ឋានថវិកានីយកម្ម និងនាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣២៧២
២៥-០២-២០១៦ -ប្រកាសលេខ ១៧០ សហវ.ប្រក ស្តីពី ការបង្កើត និងតែងតាំងក្រុមលទ្ធកម្មរបស់អង្គភាពថវិកាថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣២៧៤
២៦-០២-២០១៦ -ប្រកាសលេខ ១៧៤ សហវ.ប្រក ស្តីពី ការបង្កើតក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ៣២៧៧

## ២-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២០-០១-២០១៦ -ប្រកាសលេខ ១១៥៨ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម ៣២៨០

២៤-០២-២០១៦ -ប្រកាសលេខ ២០៨៤ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម ៣២៨១

២៤-០២-២០១៦ -ប្រកាសលេខ ២០៨៥ ប្រក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីសមាគម ៣២៨២

## ៣-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

០៨-៤-២០១៦ -សេចក្តីសម្រេចលេខ ០២៥ ស.ស.រ. ស្តីពី ការបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី ៣២៨៣

## ៤-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

៣០-១២-២០១៥ -ប្រកាសលេខ ៧៤៧ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាង លីង ស្រេដ បង្កើតរោងចក្រ ខារអំបោះ ៣២៨៥

៣១-១២-២០១៥ -ប្រកាសលេខ ៧៤៨ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កំពង់ កន្ទួត មេឌូហ្វេកធើរីង (ខេមបូឌា) ខូអិលធីឌី បង្កើតរោងចក្រ ផលិតកេសកាតុង និងផលិតផលផ្សេងៗពីក្រដាស ៣២៨៨

៣១-១២-២០១៥ -ប្រកាសលេខ ៧៤៩ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខ្មែរ ប្រ៊ីវើរី លីមីធីត បង្កើតរោងចក្រ ផលិតទឹកក្រូច-ទឹកផ្លែឈើ និងទឹកបរិសុទ្ធ ៣២៩១

៣១-១២-២០១៥ -ប្រកាសលេខ ៧៥០ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៉ាស៊ីហ្វិក អឹភើរីល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៣២៩៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បញ្ចប់មុខតំណែងឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **គុយ ម៉ិនសន** អត្តលេខ ០០០១ ពីអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ។

**មាត្រា ២** : តែងតាំងនិងផ្តល់ឋានៈឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **គុយ ម៉ិនសន** អត្តលេខ ០០០១ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦៣. ៣៦៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៣៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្ទេរក្របខ័ណ្ឌឯកឧត្តម **ចាន់ គឹមសេង** ពីឋានន្តរសក្តិ ឧត្តមសេនីយ៍ឯក អត្តលេខ ០១១៤ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា មកក្នុងឋានន្តរសក្តិ ឧត្តមអគ្គាអនុរក្ស ថ្នាក់លេខ១ អត្តលេខ ២៥២៥នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : តែងតាំងមុខតំណែងឯកឧត្តម ឧត្តមអគ្គានុរក្ស ថ្នាក់លេខ១ **ចាន់ គឹមសេង** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៣៥៥ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម បានត្រឹមត្រូវ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៧.១៦០៣.៣៦៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

- ឯកឧត្តម **ខាយ ឃុនហេង**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- លោកជំទាវ **រស់ សូរគ្នា** | ៣- ឯកឧត្តម **ជុន វ៉ាត** |
| ២- ឯកឧត្តម **ភាន ច័ន្ទមេត្តា** | ៤- ឯកឧត្តម **ញាន ស្រស់** |

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | |
|---|---|
| ១- លោកជំទាវ **ម៉ី គឿង** | ១៣- លោក **ប៉ាល់ ទុឡ្យីកា** |
| ២- ឯកឧត្តម **ម៉ូវ ចរិយា** | ១៤- លោកស្រី **អាន គីមឈុន** |
| ៣- ឯកឧត្តម **អោក បូរ៉ា** | ១៥- លោក **មាស ចំរើន** |
| ៤- ឯកឧត្តម **លីវ គីមហេង** | ១៦- លោកស្រី **ម៉ម សារី** |
| ៥- ឯកឧត្តម **ជា មានិត** | ១៧- លោក **សាល់ ស៊ីថារិទ្ធិ** |
| ៦- លោកស្រី **មុំ ប្រណិត** | ១៨- លោក **លី មុនីនាថ** |
| ៧- លោក **ឆេព ប៊ុន្ថា** | ១៩- លោក **អ៊ុក ភារុណ** |
| ៨- លោក **ឆូក ជារិទ្ធ** | ២០- លោក **សាម ណុក** |
| ៩- លោក **ម៉ៅ ផល្លា** | ២១- លោក **យស់ សុផា** |
| ១០- លោក **ឈី សុខា** | ២២- លោក **អ៊ូ នៃ** |
| ១១- លោក **ព្រាប សុរិទ្ធី** | ២៣- លោក **រិន សុខុម** |
| ១២- លោក **យី វឌ្ឍឫទ្ធិ** | ២៤- លោក **ឡាយ សុមេធី** |

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | |
|---|---|
| ១- ឯកឧត្តម **ឡាយ សំគុល** | ៣- ឯកឧត្តម **លី រ៉ាស៊ី** |
| ២- ឯកឧត្តម **ព្រុំ សុន្ធរ** | |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១- លោកជំទាវ លឹប លឿង
២- ឯកឧត្តម គិម ទិវ្យា
៣- លោក ឡាយ គួក
៤- លោក ប៊ុក សុផាត
៥- លោក សរ រតនា
៦- លោក ហ៊ុយ សារិន
៧- លោក គឹម ឈន
៨- លោក ស គន្ធា
៩- លោកស្រី ញាន និត្យចិន្តា

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

- លោកជំទាវ ប្រាក់ ចំនួណយ

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តម ចាយ ណាធុន
២- លោកជំទាវ ជ្រឹង បុទុមរង្សី
៣- ឯកឧត្តម អេ សុតា
៤- ឯកឧត្តម ខូច មករា
៥- ឯកឧត្តម សេក សុជាតិ

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- ឯកឧត្តម ហ៊ិន សារឿន
២- ឯកឧត្តម ផន ចំរើន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.១៦០៣.៣៦៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦

លេខ: ៣៥៩ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **និតជឺ អើប ហ្វ្រែនស៊ីសុស** (SCHNITGER ARP FRANCISCUS) ជនជាតិហូឡង់ សញ្ជាតិហូឡង់ កើតថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៦៧ នៅទីក្រុងហាមលេម ព្រះរាជាណាចក្រហូឡង់ ដោយសុំប្តូរឈ្មោះជា **តាន់ សំបូរ** (TANN SAMBO)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១២០៣-៣២៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៣៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អ៊ូ ជីនជួង** (WU JINZHUANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៥ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៣. ៣៦៦

លេខៈ ៣៥២ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦*

**សំណៅចំលងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៣៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម **ចាន់ វ៉ែន** ២- ឯកឧត្តម **គឹម សាន្ត**

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **ប្រាក់ ឈឿង** ២- លោក **ចាន់ ស៊ីណា**
៣- លោក **អ៊ុក ផល្លា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៦៣.៣៦៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៣៧៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ សហភាពសហព័ន្ធយុវជនកម្ពុជា ( ស.ស.យ.ក. ) ដែលមានគុណបំណាច់ និងស្នាដៃដ៏ធំធេងក្នុងការប្រមូលផ្តុំ បង្រួបបង្រួម ទំនាក់ទំនងជាមិត្តភាព សហប្រតិបត្តិការទូលំទូលាយ ជាមួយយុវជនទាំងក្នុង និងក្រៅប្រទេស ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈសង្គម និងនិន្នាការនយោបាយ ជាកម្លាំងមហាសាមគ្គីក្នុងការចូលរួមចំណែកកសាង និងការពារព្រះរាជាណាចក្រកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ឲ្យមានកិត្តិនាម កិត្យានុភាពលើឆាកអន្តរជាតិ។

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មហាសេរីវឌ្ឍន៍ឯករាជជាតិ ព្រះរាជាណាចក្រកម្ពុជា**

**ចំពោះ**

**សហភាពសហព័ន្ធយុវជនកម្ពុជា**
**( ស.ស.យ.ក. )**

នរោត្តម សីហមុនី

៣រស.១៦០៤.៣៦៤

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០៥៨/១៦ រ.វ. ចច
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ជូន ឯកឧត្តម **គុយ សុផល** ដែលមានអតីតភាពបម្រើការងាររដ្ឋ ៣៧ ឆ្នាំ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ តទៅ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣នល.១៦០៤.៣៦៩

លេខ ៣៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកប/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **អ៊ុក ធាវី** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣នស. ១៦០៤. ៣៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៣៦៤ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើមសម្រាប់ការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៤១៦/៣៦៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **មូហាម៉ាត់ស៊ើន មូសា** (MOHAMAD ZAIN MUSA) ជាទីប្រឹក្សារាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៦០៤. ៣៧១

លេខ: ៣៦១ ស.ណ
**សំណៅចែលមានត្រឹមត្រូវតាមការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

នូវ

**គ្រឿងឥស្សរិយយស ជាតូបការ :**

១- លោកជំទាវ **សួន ស្រីនួច**
២- លោកស្រី **ហ៊ឹម លន់**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រសរ. ១៦០៤.៣៧៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៣៦៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស័យ សុខា**

នស/រកត/០៤១៦/៣៦៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤  ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១  ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤  ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : **បញ្ចប់មុខងារ ៖**

១- ឯកឧត្តម **គាត ឈន់** ជាឧបនាយករដ្ឋមន្ត្រីប្រចាំការ តាមសំណើរបស់សាមីឥស្សរជន

២- ឯកឧត្តម **ហោ ណាំហុង** ជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តាមសំណើរបស់សាមីឥស្សរជន ដោយរក្សាទុកមុខងារជា ឧបនាយករដ្ឋមន្ត្រី

៣- ឯកឧត្តម **អ៊ឹម ឈុនលឹម** ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់សាមីឥស្សរជន ។

**មាត្រា ២** : **តែងតាំង ៖**

១- ឯកឧត្តម **ប្រាក់ សុខុន** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣- ឯកឧត្តម **ស៊ុន ចាន់ថុល** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

៤- ឯកឧត្តម **ជា សុផារ៉ា** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៥- ឯកឧត្តម **ហ៊ឹម ឆែម** ជា ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

៦- ឯកឧត្តម **មិន ឃិន** ជា ទេសរដ្ឋមន្ត្រី ( ទទួលបន្ទុកបេសកកម្មពិសេស)

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS
ព្រះបរមរាជវាំង

៧- ឯកឧត្តម **អ៊ឹម សូស៊ី** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៨- ឯកឧត្តម **វេង សាខុន** ជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៩- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** ជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

១០- ឯកឧត្តម **ប៉ាន សូរស័ក្តិ** ជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១- ឯកឧត្តម **ត្រាំ អ៊ីវតឹក** ជា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១២- ឯកឧត្តម **ឈិត សុខុន** ជា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

១៣- ឯកឧត្តម **ខូយ ឃុនហ៊ួរ** ជា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

១៤- ឯកឧត្តម **ប៉ាច ហមផាន** ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

១៥- ឯកឧត្តម **ជៀង អំ** ជា រដ្ឋលេខាធិការក្រសួងការពារជាតិ

១៦- ឯកឧត្តម **អ៊ី ឈាន** ជា រដ្ឋលេខាធិការក្រសួងការពារជាតិ

១៧- ឯកឧត្តម **លុយ ដាវីត** ជា រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១៨- ឯកឧត្តម **ណៅ ធួក** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៩- ឯកឧត្តម **លី ផល្លា** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២០- ឯកឧត្តម **ហាស់ សារ៉េត** ជា រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២១- ឯកឧត្តម **អ៊ូ សំអូន** ជា រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ

២២- ឯកឧត្តម **ផៃ ប៊ុនឈឿន** ជា រដ្ឋលេខាធិការក្រសួងបរិស្ថាន

២៣- ឯកឧត្តម **គោស៊ុំ សារឿត** ជា រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម

២៤- ឯកឧត្តម **ផែង សុវិជ្ជានោ** ជា រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

២៥- ឯកឧត្តម **ជួន ចន** ជា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស. ១៦០៤.៣៧៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៣៦០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទូរគមនាគមន៍
- បានទ្រង់យល់អនុក្រឹត្យលេខ ៤៥អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែង ៖

១-ឯកឧត្តម **ជុន ហ៊ាត** ពី អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២-ឯកឧត្តម **ជា មានិត** ពី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ២** : តែងតាំង ៖

១- ឯកឧត្តម **ជា មានិត** ជា អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

២- ឯកឧត្តម **ជុន ហ៊ាត** ជា អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរស.១៦០៤.៣៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦

លេខ: ៣៧៤ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ **សូ ស្រីម៉ិច** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៦០៤.៣៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦*

លេខៈ ៣៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៣៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម / ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឃឹម ស៊ីវទន្ស** ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរណ. ១៦០៤.៣៧៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦*

លេខ: ៣៧១ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៥៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣២៦ ០០០ ០០០ រៀល (បីរយម្ភៃប្រាំមួយលានរៀលគត់) ពីជំពូក៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ចំនួន ៩៦ ០០០ ០០០ រៀល និងជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ចំនួន ២៣០ ០០០ ០០០ រៀល របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដោះស្រាយបញ្ហាជាមួយស្ត្រីយាមស្ថានទូតកម្ពុជានៅទីក្រុង Cario ប្រទេសអេហ្ស៊ីបចំនួន ២៣០លានរៀល និងទិញរថយន្តមួយគ្រឿងជូនស្ថានទូតកម្ពុជាប្រចាំនៅប្រទេសឡាវចំនួន ៩៦លានរៀល។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :......៥៤......អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៧៨ ១០០ ០០០ រៀល (ចិតសិបប្រាំបីលានមួយរយពាន់រៀលគត់) ពីជំពូក៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ផ្តល់ជូនគណៈប្រតិភូចំនួន ០៥ រូប ទៅចូលរួមសន្និសីទអន្តរជាតិស្តីពីមេរោគអេដស៍និងជំងឺអេដស៍ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី១២ នៅទីក្រុងដាកានៃប្រទេសបង់ក្លាដែស។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៥៨...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ ជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរស័ក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលនិងមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនិងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ដើម្បីធានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាព និងការបង្កើនផលិតភាពការងារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅរៀបចំកែសម្រួលនិងដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា៤ .-**

ប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃមុខតំណែង ដូចមានក្នុងតារាងខាងក្រោម ៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គនាយក | ១ ៧៥០ ០០០ |
| ២ | អគ្គនាយករង | ១ ៤០០ ០០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៧០០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន<br>ប្រធានមណ្ឌលអប់រំកែប្រែ<br>ប្រធានពន្ធនាគាររាជធានី ខេត្ត | ៦០០ ០០០ |
| ៥ | ប្រធានការិយាល័យថ្នាក់កណ្តាល<br>អនុប្រធានមណ្ឌលអប់រំកែប្រែ<br>អនុប្រធានពន្ធនាគាររាជធានី ខេត្ត | ៤២០ ០០០ |
| ៦ | អនុប្រធានការិយាល័យថ្នាក់កណ្តាល<br>ប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>ប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ៣១០ ០០០ |
| ៧ | ប្រធានផ្នែកថ្នាក់កណ្តាល<br>អនុប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>អនុប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ២៥០ ០០០ |
| ៨ | អនុប្រធានផ្នែកថ្នាក់កណ្តាល<br>ប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>ប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ២១០ ០០០ |
| ៩ | នាយត្រួតថ្នាក់កណ្តាល<br>អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>អនុប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ១៩០ ០០០ |
| ១០ | នាយត្រួតរងថ្នាក់កណ្តាល<br>ប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>ប្រធានក្រុមពន្ធនាគាររាជរាជធានី ខេត្ត | ១៨៥ ០០០ |
| ១១ | អនុប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>អនុប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត | ១៨០ ០០០ |
| ១២ | មន្ត្រីពន្ធនាគារ | ១៥០ ០០០ |

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រា៥ .-**

ក្នុងករណីប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ទាបជាងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលកំពុងទទួលបានបច្ចុប្បន្ន ប្រាក់បង្គ្រប់នឹងត្រូវអនុវត្តបន្ថែមលើប្រាក់បំណាច់មុខងារឱ្យមានចំនួនស្មើនឹងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលកំពុងទទួលបានបច្ចុប្បន្ន។

**មាត្រា៦ .-**

មន្ត្រីពន្ធនាគារដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងតំណែងនោះ។ ករណីមន្ត្រីពន្ធនាគារដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់។

**មាត្រា៧ .-**

ការកែប្រែចំនួនមុខតំណែងឬប្រាក់បំណាច់មុខងារដូចមានចែងក្នុងមាត្រា៤ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

មន្ត្រីពន្ធនាគារដែលមានសិទ្ធិទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈឬបច្ចេកទេសតាមតម្រូវការរបស់រដ្ឋ
- កំពុងបំពេញកម្មសិក្សាជាដំបូងដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ
- កំពុងបំពេញការងារក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់ក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺនិងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៩ .-**

ការបញ្ឈប់ការបើកផ្តល់ប្រាក់បំណាច់មុខងារ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីពន្ធនាគារសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីពន្ធនាគារដែលត្រូវបានដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- មន្ត្រីពន្ធនាគារដែលមានប្រកាសបណ្តេញចេញពីក្របខណ្ឌមន្ត្រីពន្ធនាគារ
- មន្ត្រីពន្ធនាគារដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីពន្ធនាគារពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីពន្ធនាគារដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

**មាត្រា១០ .-**

របបឧបត្ថម្ភផ្សេងៗទៀតក្រៅពីប្រាក់បំណាច់មុខងារ  ត្រូវបន្តអនុវត្តជាធរមានរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី**<br>**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ  នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា  និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា  ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ៣២ សសរ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១
## ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា "ក.អ.ក" មានសមាសភាពដូចតទៅៈ

| | |
|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម ជិន ប៊ុនស៊ាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួង រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| ១៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង | សមាជិក |
| ២០- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង | សមាជិក |
| ២១- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង | សមាជិក |
| ២២- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង | សមាជិក |
| ២៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

រដ្ឋមន្ត្រី ឬប្រធានស្ថាប័នឯទៀត នៃរាជរដ្ឋាភិបាល ត្រូវចូលរួមក្នុងការប្រជុំរបស់ "ក.អ.ក " តាមការអញ្ជើញរបស់ប្រធាន។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួន ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សា និងការសម្រេច។

**មាត្រា២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ "គ.ស.ព" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៤- អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក"។

**មាត្រា៣ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងអគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានអគ្គលេខាធិការរងមួយចំនួនរៀងៗខ្លួនសម្រាប់ជាជំនួយការក្នុងការងារ។ អគ្គលេខាធិការរងនីមួយៗ ត្រូវបំពេញកិច្ចការតាមភារកិច្ចដែលអគ្គលេខាធិការប្រគល់ឱ្យ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ។ អគ្គលេខាធិការមួយរូបៗត្រូវបំពេញការងារដោយផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន។

**មាត្រា៤ .-**

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ

២- ផ្នែកឯកសារ និងគ្រប់គ្រងព័ត៌មាន

៣- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ល។)

៦- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និងបណ្តាស្ថាប័ននៃអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកគ្រប់គ្រងសម្របសម្រួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោងសហប្រតិបត្តិការ

៩- ផ្នែកភាពជាដៃគូ និងសុខដុមភាវូបនីយកម្មនៃកិច្ចសហប្រតិបត្តិការ
១០-ផ្នែករដ្ឋបាល។

**មាត្រា៥ .-**

គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖
១- ផ្នែកទំនាក់ទំនងសាធារណៈ និងការជំរុញគម្រោងវិនិយោគឯកជន
២- ផ្នែកវិភាគគម្រោង និងការលើកទឹកចិត្ត
៣- ផ្នែកវាយតម្លៃខាងបរិស្ថាន
៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង
៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន
៦- ផ្នែកនីតិកម្ម និងច្បាប់វិនិយោគ
៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ
៨- ផ្នែករដ្ឋបាល។

**មាត្រា៦ .-**

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖
១- ផ្នែកគោលនយោបាយ និងផែនការ
២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង
៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង
៤- ផ្នែករដ្ឋបាល។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" រួមមាន "ផ្នែកគាំទ្រ" ចំនួន ៤៖
១- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
២- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ
៣- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក
៤- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

**មាត្រា៨ .-**

ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូបជាជំនួយការ។

**មាត្រា៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ។
គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ៖
១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

## ជំពូកទី ២
## សមត្ថកិច្ច និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ៖

១- ជាសេនាធិការ និងជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

២- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើឱ្យគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។

៣- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។

៤- តម្រង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា។

៥- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ។

៦- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ គម្រោងវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា១១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ៖

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា១២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន។

**មាត្រា១៣ .-**

ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅៈ

១- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទងជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍។

៣- កៀរគរ និងវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ។

៤- ដឹកនាំផ្ទាល់កិច្ចការដែលពាក់ព័ន្ធនឹងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះ។

៦- រៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំកម្រិតគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ ដូចជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និង "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ។

៧- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមវិស័យសម្រាប់អភិវឌ្ឍន៍កម្ពុជា។

៨- ចូលរួមគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា។

៩- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីទទួល និង/ឬបែងចែកហិរញ្ញប្បទានទាំងនោះ។

១០-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

**មាត្រា១៤ .-**

ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" ជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្អួចការទូតផ្លូវការ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ព្រមទាំងទទួលបន្ទុកចៀរគរ និងគ្រប់គ្រងដោយផ្ទាល់នូវហិរញ្ញប្បទានជាការខ្ចី និងជំនួយបច្ចេកទេសដែលមានការពាក់ព័ន្ធ។

៥- ក្រសួងជំនាញជាអ្នករៀបចំផែនការអភិវឌ្ឍន៍ និងគម្រោងវិនិយោគសាធារណៈតាមវិស័យដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ, ជាមួយ "ក.អ.ក" និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៥ .-**

ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួន ខាងការវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៦ .-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តកម្មវិធី និង/ឬគម្រោងស្របតាមសមត្ថកិច្ចរៀងៗខ្លួនដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ។

**មាត្រា១៧ .-**

ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ "ការប្រណាំងប្រជែងដណ្តើមឈ្មុះ" លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចឱ្យបាននូវទស្សនៈនេះដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជា "សាជីវកម្មកម្ពុជា"។ សហការ

ជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកវិនិយោគ តាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានាដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

**មាត្រា១៨ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជនដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅៈ

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគម្រោងខ្លះមិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជនដែល "ក.អ.ក" បានផ្តល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២១ .-**

ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាពរដ្ឋ ឯកជនចម្រុះរដ្ឋ និងឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចឱ្យបាននូវទស្សនៈនេះ ដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានាដែលមានប្រសិទ្ធភាព និងឆាប់រហ័ស។

៤- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការកែលម្អច្បាប់បទប្បញ្ញត្តិនានា និងដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរនានា និងការធ្វើអធិការកិច្ចចំពោះតំបន់សេដ្ឋកិច្ចពិសេស។

៧- ចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស និងតម្រង់ទិសការងារវិនិយោគតំបន់។

**មាត្រា២២ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

៣- "ក.អ.ក" សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា២៣ .-**

ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅៈ

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក"

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងនៃអង្គប្រជុំពេញអង្គរបស់ "ក.អ.ក"

៣- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"

៤- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ "ក.អ.ក"។

**មាត្រា២៤ .-**

នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់លើការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និងការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ។

**មាត្រា២៥ .-**

អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅៈ

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន "ក.អ.ក" អវត្តមាន។

២- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "ក.អ.ក"។

៣- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសម្របសម្រួលជាមួយប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។

៤- ទទួលបន្ទុកសម្របសម្រួលការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ជាមួយគូអង្គអភិវឌ្ឍន៍ដោយសហការជិតស្និទ្ធជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

៥- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្តោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៅក្នុងដែនសមត្ថកិច្ចនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

៦- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ ជំរុញការវិនិយោគឯកជន និងកិច្ចការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយការងារអភិវឌ្ឍន៍វិស័យឯកជន យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រនេះ។

៧- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយ "គ.វ.ក" ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" លើការងារវិនិយោគឯកជន។

៨- ទទួលបន្ទុកពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជនដែលមានលក្ខណៈសាមញ្ញ ដូចជារោងចក្រកាត់ដេរ រោងចក្រស្បែកជើង និងឧស្សាហកម្មគាំទ្រជាដើម ព្រមទាំងបណ្តាគម្រោងដែលមិនទាមទារការលើកទឹកចិត្តផងដែរ។

៩- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ានដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន។

១០-ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង "ក.អ.ក" ជាមួយនឹងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល។

១១-បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៦ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក"។

២- ទទួលបន្ទុកសម្របសម្រួល និងតាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាសេនាធិការបច្ចេកទេសឱ្យ "ក.អ.ក" ក្នុងការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

៤- រៀបចំកម្មវិធីការងាររបស់ "ក.អ.ក" និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗសម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៥- សម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូន គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគឯកជន ។

៧- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន"។

៨- បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៧ .-**

អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅៈ

១- គ្រប់គ្រងការងាររបស់ "គ.ជ.នា"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍។

៣- រៀបចំ និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងជាអ្នកដឹកនាំរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ។

៤- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" និងយន្តការពិគ្រោះយោបល់ដទៃទៀត។

៥- ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ និងចុះហត្ថលេខាលើកម្មវិធីសហប្រតិបត្តិការឥតសំណងទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍។

៦- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៧- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៨- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេចមុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៩- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៨ .-**

អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅៈ

១- គ្រប់គ្រងការងាររបស់ "គ.វ.ក"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការវិនិយោគឯកជន។

៣- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៥- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល។

៦- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

៧- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ដែលប្រធាន ឬ អនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៩ .-**

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.ស.ព"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ"។

៤- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំពេញអង្គរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៥- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងការវិវត្តនៃគម្រោងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលមានការពាក់ព័ន្ធ ហើយធ្វើ

របាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់។

៦- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ លើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល។

៧- បំពេញការងារដទៃទៀត ដែលទាក់ទងនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា៣០ .–**

សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយ កម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តទាំងខាងផ្នែកសាធារណៈទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**មាត្រា៣១ .–**

ក្នុងករណីចាំបាច់ប្រធាន "ក.អ.ក" អាចកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ឬប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"។

**មាត្រា៣២ .–**

ការប្រព្រឹត្តទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៣ .–**

ការអនុវត្តការងារនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគឯកជន និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ដូចខាងក្រោម៖

ទី១- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា៖

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូប ឱ្យមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្ថិតរមួតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ជ.នា" ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ជ.នា" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង-អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី២- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជា៖

ក-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការវិនិយោគកម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន

- ស្ទិតរម្មតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.វ.ក" ចំពោះតែកិច្ចការវិនិយោគឯកជនណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.វ.ក" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៣- សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា៖

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួង រ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ទិតរម្មតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្ទិតរម្មតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ស.ព" ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ។

គ-អគ្គលេខាធិការ "គ.ស.ព" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាផរមានហើយ អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង-អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៤- ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងព័ត៌មានផ្សេងៗពីអគ្គលេខាធិការ "គ.ជ.នា" អគ្គលេខាធិការ "គ.វ.ក" អគ្គលេខាធិការ "គ.ស.ព" មក អគ្គលេខាធិការ "ក.អ.ក" ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

**មាត្រា៣៤ .–**

សេចក្តីលម្អិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក "។

**មាត្រា៣៥ .–**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និងមានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន។ ការគ្រប់គ្រងចំណូល និងចំណាយថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៣៦ .–**

អនុក្រឹត្យនេះ ជំនួសអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣។

**មាត្រា៣៧ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈ

អភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលគ្រប់ខេត្តទាំងអស់ និងសមាសភាព ដូចមានក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៣១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា ១** : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម ៖

១-លោក **លឿង រដ្ឋា**

២-លោក **ហេង ណាន** ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### សម្រេច

**មាត្រា ១.**_បំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន៥៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

១-លោក **មាស កុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
២-លោកស្រី **រស់ សារ៉ុន** ប្រធានការិយាល័យសារពើភ័ណ្ឌនៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ
៣-លោក **ស្រី សារឿន** កែវអនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតា

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា**

១-លោកស្រី **ឆេព វ៉ូដា** អគ្គនាយករង
២-លោក **ហ៊ី ករុណា** ប្រធាននាយកដ្ឋាន
៣-លោក **ច្រាក់ គារ៉ាទុធ** ប្រធាននាយកដ្ឋាន
៤-លោក **ទ៉ែត លាភ** អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
៥-លោក **គ្រុយ សុខា** អនុប្រធាននាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៦-លោក **ថាន់ សុជាតិ** អនុប្រធាននាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
៧-លោក **ហៃ ទឿន** ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៨-លោក **កុយ សុវណ្ណា** ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ
៩-លោកស្រី **នួន យិនសារឿន** អនុប្រធានការិយាល័យសម្ភារៈ និងប្រេងឥន្ធនៈនៃនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ
១០-លោកស្រី **មុត សំអាង** អនុប្រធានការិយាល័យពិធីការនៃនាយកដ្ឋានរដ្ឋបាល
១១-លោក **នុត សាំងទេង** ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តក្រចេះ
១២-លោក **ប៉ែន ចាន់វិទ្ធា** មន្ត្រីការិយាល័យបទស្រុកស្រែអំបិលនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកោះកុង.
១៣-លោក **សៅ ចន្ថា** មន្ត្រីការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកោះកុង

១៤-លោកស្រី **ផាន់ ណារឿន** មន្ត្រីការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់

**គ-មេដាយ សុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

១-លោក **អ៊ុច មនោរ័ត្ន** ប្រធាននាយកដ្ឋាន

២-លោក **ចាន់ លីហ៊ា** ប្រធាននាយកដ្ឋាន

៣-លោក **សុខ ថេង** អនុប្រធាននាយកដ្ឋាន

៤-លោកស្រី **ណឹម ថូ** អនុប្រធាននាយកដ្ឋាន

៥-លោក **ប៊ូ ប៊ុនធឿន** អនុប្រធាននាយកដ្ឋាន

៦-លោក **ឡាយ គីមឡុង** ប្រធានការិយាល័យ

៧-លោក **ឃុន សុផល** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

៨-លោកស្រី **សារ៉េត គេសរកុល** អនុប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ

៩-លោកស្រី **ស្រី ចិន្តា** ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១០-លោកស្រី **ប៉ែន ចិន្តា** ប្រធានការិយាល័យសវនកម្មផ្ទៃក្នុងទី៤នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១១-លោក **អ៊ួច សារ៉ាត់** ប្រធានការិយាល័យរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃនាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

១២-លោក **សំ មុយ** អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល

១៣-លោក **ខ្លូច សុវិទ្ធី** មន្ត្រីការិយាល័យបុគ្គលិកនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល

១៤-លោក **កៅ តារិត** មន្ត្រីការិយាល័យគ្រប់គ្រងសេវាពាណិជ្ជកម្មនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៥-លោក **សួន គីមស្រ៊ុន** មន្ត្រីការិយាល័យគ្រប់គ្រងសេវាពាណិជ្ជកម្មនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៦-លោកស្រី **យុន វត្តី** មន្ត្រីការិយាល័យសិក្សាផ្ទៃសេវាប្រៃសណីយ៍នៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៧-លោកស្រី **នូ ណារី** មន្ត្រីការិយាល័យរដ្ឋបាល នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល

១៨-លោក **យឹម ស្វ** មន្ត្រីការិយាល័យរដ្ឋបាល នៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

១៩-លោកស្រី **ឡុក វុតនី** មន្ត្រីនៃមហាវិទ្យាល័យគ្រប់គ្រងប្រៃសណីយ៍ និងភស្តុភារ

២០-លោកស្រី **ចាប សុជាតា** មន្ត្រីនៃមហាវិទ្យាល័យគ្រប់គ្រងប្រៃសណីយ៍ និងភស្តុភារ

២១-កញ្ញា **ចាន់ សោភី** នាគមន៍ខេត្តសៀមរាបអនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគម

២២-លោក **ចាន់ សុគុន** អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

២៣-កញ្ញា **ហ៊ិន សុភាព** អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ

២៤-លោក **កើត វ៉ែន** អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ

២៥-លោក **ហៃ ហន** ប្រធានការិយាល័យប្រៃសណីយ៍ នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

២៦-លោកស្រី **ឌុយ ទេព** ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកណ្តាល

២៧-លោក **សេង ប៊ុនឡា** ប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ

២៨-លោក **ខៀវ ម៉ាង** ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ

២៩-លោក **សាន ឧុធធឿន** ប្រធានការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តព្រះសីហនុ

៣០-លោក **លឹម ហាក់** ទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំប្រធានការិយាល័យ

៣១-លោក **សេង ខួន** ប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ

៣២-លោក **ផេង វ៉ា** ប្រធានការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

៣៣-លោក **ឡាំ ពៅ** អនុប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃណីយ៍ និងទូគមនាគមន៍ខេត្តកោះកុង

៣៤-លោក **សំ ប៊ុនធឿន** មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តកោះកុង

៣៥-លោក **យក់ ចាន់** មន្ត្រីនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តត្បូងឃ្មុំ

៣៦-លោក **ឈឹម សាទិន** មន្ត្រីការិយាល័យប.ទស្រុកកោះសូទិន នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ០៤ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៣៣...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយការងារ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួន២៦៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

១-លោក ហេង ម៉ារ៉ា អនុប្រធាននាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

២-លោក ប៉ែន ពុទ្ធា អនុប្រធាននាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

៣-លោកស្រី អ៊ុំ ម៉ូលីកា ជំនួយការរដ្ឋមន្ត្រីមានឋានៈស្មើអនុប្រធាននាយកដ្ឋាន

៤-លោកស្រី គឹម ឡាង ប្រធានការិយាល័យស្តង់ដានៃនាយកដ្ឋានរដ្ឋាភិបាលអេឡិចត្រូនិច

៥-លោក ហែម រតនៈ ប្រធានការិយាល័យត្រួតពិនិត្យកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាននៃនាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

៦-លោកស្រី ឃិន ហួតអេលី ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

៧-លោក សុខ វង្សា ប្រធានការិយាល័យចុះបញ្ជីនិងផ្តល់អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាននៃនាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

៨-លោក តាន់ សុភ័ក្រ ប្រធានការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រនៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

៩-លោក អ៊ួង សុភា ប្រធានការិយាល័យហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈនៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

១០-លោកស្រី ប៉ាល សុជាវី អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១១-លោកស្រី ជា បរមម៉ាលីនី អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាល

១២-លោក សូរ ប៊ុនធឿន វិយាល័យព័ត៌មាននៃនាយកដ្ឋានរដ្ឋបាលអនុប្រធានកា

១៣-លោកស្រី ព្រំ សយនា មន្ត្រីការិយាល័យទទួលពាក្យបណ្តឹងនៃនាយកដ្ឋានអធិការកិច្ចរដ្ឋបាល និងទទួលពាក្យបណ្តឹង

១៤-លោកស្រី ជិន ចន មន្ត្រីការិយាល័យសវនកម្មទី២នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១៥-លោកស្រី អ៊ុំ សុមេធ មន្ត្រីការិយាល័យកាតព្វកិច្ចសេវាសកលប្រៃសណីយ៍នៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៦-លោកស្រី ឌុច សំអាត មន្ត្រីការិយាល័យគំរិតគុណភាព និងសុវត្ថិភាពនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៧-លោកស្រី អំ ស៊ីនួន មន្ត្រីការិយាល័យគំរិតគុណភាព និងសុវត្ថិភាពនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍

១៨-លោកស្រី សាំង មុំ មន្ត្រីការិយាល័យកំរិតគុណភាព និងសុវត្ថិភាពនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
១៩-លោកស្រី អ៊ាន ចិន្តា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
២០-លោកស្រី ខឹម ចាន់ណា ការិយាល័យរដ្ឋបាលនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍មន្ត្រី
២១-លោកស្រី អ៊ុយ ឌីណា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
២២-លោកស្រី អ៊ុង ច័ន្ទណារ័ត្ន មន្ត្រីការិយាល័យកិច្ចការអាស៊ាននៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២៣-លោកស្រី ឈុំ ច័ន្ទតារា មន្ត្រីការិយាល័យសហប្រតិបត្តិការពហុភាគីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២៤-លោកស្រី អាន ម៉េងហ៊ុន មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២៥-លោក មាស ច័ន្ទសុផល អនុប្រធានការិយល័យនីតិកម្មនៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
២៦-លោកស្រី វ៉ាន់ ណាយ៉ន មន្ត្រីការិយល័យនីតិកម្មនៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
២៧-លោកស្រី ឡុង ចន្នី មន្ត្រីការិយល័យគោលនយោបាយទូរគមនាគមន៍នៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
២៨-លោកស្រី ជិន ស៊ិដេត មន្ត្រីការិយល័យធនធានទូរគមនាគមន៍នៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
២៩-លោក ណាំ គីមឡេង មន្ត្រីការិយល័យធនធានទូរគមនាគមន៍នៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
៣០-លោកស្រី សោភ័ណ អមរា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣១-លោកស្រី តៃ លីណាដារី មន្ត្រីការិយាល័យប្រៃសណីយ៍និយ័តនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣២-លោកស្រី ណុប ថានី មន្ត្រីការិយាល័យគោលនយោបាយប្រៃសណីយ៍នៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៣-លោកស្រី សុខ លីស មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៤-លោកស្រី អ៊ុង បូរិទ្ធរស្មី មន្ត្រីការិយាល័យគោលនយោបាយប្រៃសណីយ៍នៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៥-លោកស្រី តែត ចន្ថារី មន្ត្រីការិយាល័យគោលនយោបាយប្រៃសណីយ៍នៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៦-លោកស្រី ហ៊ីម សុខុម មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៧-លោក សាន ស៊ីថា មន្ត្រីការិយាល័យប្រៃសណីយ៍និយ័តនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៨-លោកស្រី អន សុគន្ធទេវី មន្ត្រីការិយាល័យគោលនយោបាយប្រៃសណីយ៍នៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៣៩-លោកស្រី ហ៊ួត ស៊ីនឿន មន្ត្រីការិយាល័យប្រៃសណីយ៍សកលនៃនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍
៤០-កញ្ញា ព្រឿង សានី មន្ត្រីការិយាល័យពិធីការនៃនាយកដ្ឋានរដ្ឋបាល
៤១-លោកស្រី ឈុន លាង យកដ្ឋានរដ្ឋបាលមន្ត្រីការិយាល័យរដ្ឋបាលនៃនា
៤២-លោក ពេញ សុផល មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាល
៤៣-លោកស្រី កែវ លក្ខិណា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាល
៤៤-លោកស្រី ញ៉ែម គន្ធមុនី មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៤៥-លោកស្រី សែម សីលា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
៤៦-លោក ឯម រតនា មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
៤៧-លោក ខូយ ពិសិដ្ឋ មន្ត្រីការិយាល័យកាតព្វកិច្ចសេវាសកលនៃនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជនបទ
៤៨-លោក រឿង សារុន មន្ត្រីការិយាល័យសម្ភារៈបច្ចេកទេសបណ្តាញនៃនាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន និងគ្រប់គ្រងប្រព័ន្ធវិជ្ជមាននៃសន្និសីទរបស់រាជរដ្ឋាភិបាល
៤៩-លោក អ៊ូ សំសោភ័ណ មន្ត្រីការិយាល័យចុះបញ្ជីនិងផ្តល់អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាននៃនាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
៥០-លោក ឡឹក វិសាល មន្ត្រីការិយាល័យនិយាមត្រួតពិនិត្យ និងហានិភ័យនៃនាយកដ្ឋានសន្តិសុខ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌ម
៥១-លោក ឡេង សុធារ៉ា មន្ត្រីការិយាល័យធានាគុណភាព និងកោសលវិច័យឌីជីថលនៃនាយកដ្ឋានសន្តិសុខ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
៥២-លោក ហេង ស៊ីរ៉ាវិទ្ធ មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
៥៣-លោកស្រី ខា ម៉ូលីដា មន្ត្រីនៃមហាវិទ្យាល័យគ្រប់គ្រងប្រៃសណីយ៍ និងភស្តុការ
៥៤-លោកស្រី ចាប សូរ៉ានី យ៍ និងភស្តុការមន្ត្រីនៃមហាវិទ្យាល័យគ្រប់គ្រងប្រៃសណី
៥៥-លោកស្រី នូ សុទ្ធី មន្ត្រីការិយាល័យរដ្ឋបាលនៃមហាវិទ្យាល័យបច្ចេកវិទ្យាគមនាគមន៍ និងបណ្តាញ

៥៦-លោកស្រី ថុង វណ្ណារី មន្ត្រីការិយាល័យបណ្តុះបណ្តាលបន្ត និងបរិញ្ញាបត្ររងនៃមហាវិទ្យាល័យបច្ចេកវិទ្យា គមនាគមន៍ និងបណ្តាញ

៥៧-លោក ស៊ឹម សំអាត មន្ត្រីការិយាល័យអប់រំកំរិតឧត្តម និងក្រោយឧត្តមនៃមហាវិទ្យាល័យបច្ចេកវិទ្យា គមនាគមន៍ និងបណ្តាញ

៥៨-លោកស្រី កើត ស៊ីជាម អនុប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តប៉ៃលិន

៥៩-លោក ស៊ា ប៊ុណ្ណា អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

៦០-លោក ផាន់ ពង្សមុន្នី ប្រធានការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតាកែវ

៦១-លោក ស៊ុន គ្រួច ប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគីរី

៦២-លោក អ៊ីង ស៊ាន ប្រធានការិយាល័យប.ទស្រុកសំពៅលូននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបាត់ដំបង

៦៣-លោក ពេជ្រ គិត ប្រធានការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ

៦៤-លោក តឹក ត្រា ប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ

៦៥-លោក ឆាយ យន អនុប្រធានការិយាល័យប.ទស្រុកកំរៀងនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តបាត់ដំបង

៦៦-លោក ចិន សំអាន អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតាកែវ

៦៧-លោកស្រី កៅ ចាន់សុជី អនុប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តតាកែវ

៦៨-លោកស្រី អ៊ុក ភិរុណ អនុប្រធានការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តសៀមរាប

៦៩-លោក ប៊្រូច ប៊ាន អនុប្រធានការិយាល័យប.ទស្រុកអង្គរជុំនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប

៧០-លោក ផ្លក ឈៃ អនុប្រធានការិយាល័យប.ទស្រុកសន្ទុកនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៧១-លោកស្រី យឹម សេដា អនុប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល

៧២-លោក យឹម ពៅ អនុប្រធានការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល

៧-.លោក ប៊ុន សំបូរ អនុប្រធានការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

៧៤-លោកស្រី ហ៊ិន សារឿន អនុប្រធានការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

៧៥-លោក ម៉ិល សារ៉ាត អនុប្រធានការិយាល័យប.ទស្រុកជើងព្រៃនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ចាម

៧៦-លោក នៅ ធី មន្ត្រីការិយាល័យប.ទស្រុកបារាយណ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៧៧-លោក យឿង ណាត មន្ត្រីការិយាល័យប.ទស្រុកស្ទោងនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៧៨-លោក អោ ភិច មន្ត្រីការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៧៩-លោក កុយ ៉ាឌី មន្ត្រីការិយាល័យប.ទស្រុកបារាយណ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៨០-លោក កើត ចន្ទី មន្ត្រីការិយាល័យប.ទស្រុកប្រាសាទបល្ល័ង្កនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៨១-លោក គាន ស៊ីថា មន្ត្រីការិយាល័យប.ទស្រុកស្ទោងនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

៨២-លោកស្រី គង់ វណ្ណថន មន្ត្រីការិយាល័យប.ទស្រុកកៀនស្វាយនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល

៨៣-លោកស្រី ទេស ចន្ថា មន្ត្រីការិយាល័យប.ទស្រុកកៀនស្វាយនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល

៨៤-លោក ពាក្យ មុន្នី មន្ត្រីការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកណ្តាល

៨៦-លោក ហាង ពន្លក ទស្រុកបាភ្នំនៃមន្ទីរប្រៃសណីយ៍.មន្ត្រីការិយាល័យបនិងទូរគមនាគមន៍ខេត្តព្រៃវែង

៨៧-លោក សូ ធឿន ទស្រុកបាភ្នំនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង.មន្ត្រីការិយាល័យប

៨៨-លោកស្រី អៀង យ៉ាត មន្ត្រីការិយាល័យបទស្រុកកំពង់ត្របែកនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង.

៨៩-លោក យ៉ុំ សាលីន មន្ត្រីការិយាល័យបទស្រុកកំពង់ត្របែកនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង.

៩០-លោក រ៉ា សាមុត មន្ត្រីការិយាល័យបសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែងទស្រុកកំពង់ត្របែកនៃមន្ទីរប្រៃ.

៩១លោកស្រី លាង លី មន្ត្រីការិយាល័យបទស្រុកពាមរក៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង.

៩២-លោក អ៊ាម ស៊ីណូ មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ស្ពឺ

៩៣-លោក សាន សាវ មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ស្ពឺ

៩៤-លោក ទី វឿន មន្ត្រីការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ស្ពឺ

៩៥-លោក ង៉ែត ណាន មន្ត្រីការិយាល័យប.ទ ស្រុកច្បារមននៃប្រៃសណីយ៍ និងតូរគមនាគមន៍ខេត្តកំពង់ស្ពឺ
៩៦-លោក រៀម សុំ មន្ត្រីការិយាល័យប.ទ ស្រុកច្បារមននៃប្រៃសណីយ៍ និងតូរគមនាគមន៍ខេត្តកំពង់ស្ពឺ
៩៧-លោក អ៊ិក គឹមវ៉ែន មន្ត្រីការិយាល័យប.ទ ស្រុកកំពង់ត្រាចនៃប្រៃសណីយ៍និងតូរគមនាគមន៍ខេត្តកំពត
៩៨-លោក ញ៉ឹប វុទ្ធី មន្ត្រីការិយាល័យប.ទ ស្រុកអង្គរជ័យនៃប្រៃសណីយ៍និងតូរគមនាគមន៍ខេត្តកំពត
៩៩-លោកស្រី ជួន ស៊ីថា មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពត
១០០-លោកស្រី ណយ សុគន្ធ មន្ត្រីការិយាល័យប្រៃសណីយ៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
១០១-លោក យឹម សារ៉េត មន្ត្រីការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
១០២-លោកស្រី ឃួន វ៉ាន់ដា មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
១០៣-លោក មាស សាន មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
១០៤-លោកស្រី ប៊ុត សុខា មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
១០៥-លោក ខៀវ សត្យា ប្រធានការិយាល័យ
១០៦-លោកស្រី ព្រាប ម៉ាលី អនុប្រធានការិយាល័យ
១០៧-លោកស្រី ងី សុខុម អនុប្រធានការិយាល័យ
១០៨-លោក ស៊ឹម សុផល ប្រធានសាខាប.កខេត្ត
១០៩-លោក ហេង គឹមលី ប្រធានសាខាប.កខេត្ត
១១០-លោក ប្រាក់ សាវ៉ន ប្រធានសាខាប.កខេត្ត
១១១-លោក ប៉ា សុខុម និយោជិត
១១២-លោក ឯម ឌីម៉ា និយោជិត
១១៣-លោក ថន ញ៉ និយោជិត
១១៤-លោក ឯក ភន និយោជិត
១១៥-លោក ទេព ញ៉ក់ និយោជិត
១១៦-លោក យាវ អុល និយោជិត
១១៧-លោកស្រី ឡុង ពុទ្ធារី និយោជិត
១១៨-លោកស្រី ថោង សុជារី និយោជិត
១១៩-លោកស្រី យស់ បូណេត និយោជិត
១២០-លោកស្រី សៅ នាត និយោជិត
១២១-លោកស្រី ឈុន សាន្តបូរ និយោជិត
១២២-លោកស្រី កែវ ខេន និយោជិត
១២៣-លោកស្រី ផាន់ សារ៉ាត់ និយោជិត
១២៤-លោកស្រី គីម ចាន់ថន អនុប្រធានការិយាល័យនាយកដ្ឋានរដ្ឋបាល
១២៥-លោក ប្រុក វិបុល ប្រធានផ្នែកការិយាល័យនាយកដ្ឋានរដ្ឋបាល
១២៦-លោកស្រី យៀង កន្និដ្ឋា ប្រធានផ្នែកការិយាល័យនាយកដ្ឋានរដ្ឋបាល
១២៧-លោកស្រី ឆន ម៉ាលីណា និយោជិតនាយកដ្ឋានរដ្ឋបាល
១២៨-លោក ម៉ៅ ស៊ីថុន ប្រធានមជ្ឈមណ្ឌលនាយកដ្ឋានរដ្ឋបាល
១២៩-លោកស្រី សោភ័ណ សច្ចៈ ប្រធានផ្នែកនាយកដ្ឋានរដ្ឋបាល
១៣០-លោក សួន ពិសិដ្ឋ និយោជិតនាយកដ្ឋានរដ្ឋបាល
១៣១-លោក ស្នួង វុត្ថា អនុប្រធានការិយាល័យនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ
១៣២-លោក ជឹម រត្នមុនី អនុប្រធានមជ្ឈមណ្ឌលនាយកដ្ឋានបច្ចេកវិទ្យាទូរ.និងព័ត៌មាន
១៣៣-លោក ផុំ សុខា ប្រធានផ្នែកនាយកដ្ឋានបច្ចេកវិទ្យាទូរ.និងព័ត៌មាន
១៣៤-លោក គីម គិតជាតិ និយោជិតនាយកដ្ឋានបច្ចេកវិទ្យាទូរ.និងព័ត៌មាន
១៣៥-លោក យី សុវណ្ណតារា អនុប្រធាននាយកដ្ឋានអាជីវកម្ម

| | | | |
|---|---|---|---|
| ១៣៦-លោក | ហ៊ាន | សី | ប្រធានការិយាល័យនាយកដ្ឋានអាជីវកម្ម |
| ១៣៧-លោក | ឡូ | គឹមវឿន | ខេត្តបាត់ដំបង.ក.ប្រធានសាខាទ |
| ១៣៨-លោក | ជា | សុភាព | ប្រធានការិយាល័យនាយកដ្ឋានអាជីវកម្ម |
| ១៣៩-លោក | គង់ | ដារ៉ | ប្រធានសាខាទ.ក.ខេត្តបន្ទាយមានជ័យ |
| ១៤០-លោក | ព្រុំ | គឹមសួរ | ប្រធានសាខាទ.ក.ខេត្តកំពង់ឆ្នាំង |
| ១៤១-លោក | អ៊ុង | វុឌ្ឍី | ប្រធានការិយាល័យនាយកដ្ឋានអាជីវកម្ម |
| ១៤២-លោក | ប៊ិន | ចាន់ថន | តំណាងសាខាទ.ក ខេត្តកំពង់ធំ |
| ១៤៣-លោក | វ៉ើក | សុត្ថា | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៤-លោក | ម៉ៅ | អេង | ប្រធានមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៥-លោកស្រី | ទីវ | សិទ្ធី | អនុប្រធានការិយាល័យនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៦-លោក | ឃឹម | សាវ៉ាង | អនុប្រធានមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៧-លោក | មុំ | រិន | អនុប្រធានមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៨-លោកស្រី | ទូច | លីនណា | ប្រធានផ្នែកមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៤៩-លោកស្រី | វ៉ា | វណ្ណារី | ប្រធានផ្នែកមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៥០-លោក | ហុង | សេង | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៥១-លោក | ឯក | ចំរុង | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ១៥២-លោកស្រី | អ៊ុក | ថាវី | និយោជិតនាយកដ្ឋានផែនការនិងយុទ្ធសាស្ត្រ |
| ១៥៣-លោក | វង | កល្យាណ | និយោជិតនាយកដ្ឋានផែនការនិងយុទ្ធសាស្ត្រ |
| ១៥៤-លោក | ហ៊ុយ | លីណា | និយោជិតនាយកដ្ឋានផែនការនិងយុទ្ធសាស្ត្រ |
| ១៥៥-លោកស្រី | ឃួន | ប៊ុណ្ណាត | ប្រធានផ្នែកនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |
| ១៥៦-លោកស្រី | សុខ | សំបឿន | ប្រធានផ្នែកនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |
| ១៥៧-លោក | សួស | ទីតូ | ប្រធានផ្នែកនាយកដ្ឋានបញ្ញូនស៊ីញ៉ាល់និងប.អុបទិក |
| ១៥៨-លោក | រស់ | ឌុយ | និយោជិតនាយកដ្ឋានបញ្ញូនស៊ីញ៉ាល់និងប.អុបទិក |
| ១៥៩-លោក | ផៃ | សុខុម | និយោជិតនាយកដ្ឋានបញ្ញូនស៊ីញ៉ាល់និងប.អុបទិក |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-កញ្ញា | រិទ្ធ | ដុល្លាវី | ប្រធានការិយាល័យ |
| ២-លោក | ប្រាក់ | សុវណ្ណ | ប្រធានលទ្ធកម្ម |
| ៣-លោក | ព្រហ្ម | វ៉ាសនា | ប្រធានសាខាប.កខេត្ត |
| ៤-កញ្ញា | លឹម ចាន់ណារី | | មន្ត្រីការិយាល័យសវនកម្មទី៣នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៥- លោក | ផល្លា ច័ន្ទពិសិដ្ឋ | | មន្ត្រីការិយាល័យតាមដានត្រួតពិនិត្យ និងប្រឹក្សាយោបល់នៃនាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| ៦-លោក | កែវ | ថុល | និយោជិត |
| ៧-លោក | ខៀវ | យ៉ន | និយោជិត |
| ៨-លោក | ប៊ុល | សារិន | និយោជិត |
| ៩-លោក | ង៉ុង | ចំរើន | និយោជិត |
| ១០-លោក | ស្វាយ | វ៉ាន់ | និយោជិត |
| ១១-លោក | នុត | ស្រស់ | និយោជិត |
| ១២-លោក | មាស | សាន់ដេ | និយោជិត |
| ១៣-លោក | សាត់ | សុភាព | និយោជិត |
| ១៤-លោក | អួន | សុផាត | និយោជិត |

| | | | |
|---|---|---|---|
| ១៥-លោក | អ៊ុំ | ចត់ | និយោជិត |
| ១៦-លោក | ជៀម | សារ៉ែន | និយោជិត |
| ១៧-លោក | យោ | ឆៃត្រី | និយោជិត |
| ១៨-លោកស្រី | ឯម | សំអឿន | និយោជិត |
| ១៩-លោកស្រី | អ៊ុង | សុភា | និយោជិត |
| ២០-លោកស្រី | ជា | សំភឿន | និយោជិត |
| ២១-លោកស្រី | ដេត | ភារីន | និយោជិត |
| ២២-លោកស្រី | ណឹម | លក្ខិណា | និយោជិត |
| ២៣-លោកស្រី | ឈឹម | ដារ៉េត | និយោជិត |
| ២៤-លោក | អ៊ឹម | សុភ័ក្ត្រ | និយោជិតអង្គភាពលទ្ធកម្ម |
| ២៥-លោក | ម៉ៅ | មុនីរម្យ | អនុប្រធានមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ |
| ២៦-លោក | ហួត | កុយ | និយោជិតនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ |
| ២៧-លោក | ហង់ | សុភាព | អនុប្រធានការិយាល័យនាយកដ្ឋានអាជីវកម្ម |
| ២៨-លោក | អៀត | សារ៉ានី | ប្រធានសាខាទ.ក.ខេត្តតាកែវ |
| ២៩-លោកស្រី | ខៀវ | គង្គ | ប្រធានផ្នែកនាយកដ្ឋានអាជីវកម្ម |
| ៣០-លោក | អ្នក | សម្បត្តិ | និយោជិតនាយកដ្ឋានអាជីវកម្ម |
| ៣១-លោក | អ៊ិន | វណ្ណៈ | និយោជិតនាយកដ្ឋានអាជីវកម្ម |
| ៣២-លោក | ឈិត | សម្បត្តិ | តំណាងសាខាទ.ក.ខេត្តកំពង់ចាម |
| ៣៣-លោក | ព្រុំ | សំអុន | តំណាងសាខាទ.ក.ខេត្តស្ទឹងត្រែង |
| ៣៤-លោក | ជា | សេងឡាយ | អនុប្រធានមជ្ឈមណ្ឌលនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៣៥-លោក | សុខ | សារិន | ប្រធានផ្នែកនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៣៦-លោក | សាន | សុវិចិត្រ | ប្រធានផ្នែកនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៣៧-លោក | ប៉ែន | សារិទ្ធ | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៣៨-លោក | សៅ | មុនីដារ៉ា | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៣៩-លោក | យ៉ែម | វុធរ៉ៃ | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៤០-លោក | ថោង | ខឿន | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៤១-លោកស្រី | អាន សំណាង | | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៤២-លោកស្រី | ឡេង យូថូ | | និយោជិតនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៤៣-លោកស្រី | ចាប សុខផល្លី | | និយោជិតនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |
| ៤៤-លោកស្រី | ប៉ូ ឈាងសុង | | និយោជិតនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |
| ៤៥-លោកស្រី | ហែម ស្រីកែវ | | និយោជិតនាយកដ្ឋានហិរញ្ញកិច្ចនិងគណនេយ្យ |

**គ-មេដាយសំរិទ្ធការងារ**

១-លោកស្រី ឌុម រតនា ប្រធានការិយាល័យអធិការកិច្ចហិរញ្ញវត្ថុទី២នៃនាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុ
២-លោក កយ សុខចំរើន ប្រធានការិយាល័យព័ត៌មាននៃនាយកដ្ឋានរដ្ឋបាល
៣-លោក ហ៊ាង ភ្លី អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៤-លោក ហ៊ិន សេងហាក់ អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៥-លោក ក្រូច រិទ្ធី អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៦-កញ្ញា ទេព ច័ន្ទសុភាព អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៧-លោក ប្រាក់ ស៊ីថូ អនុប្រធានការិយាល័យបៀវត្សនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៨-លោកស្រី ជា សុវណ្ណារ៉ាត់ អនុប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
៩-កញ្ញា រស់ ផារី មន្ត្រីការិយាល័យអធិការកិច្ចហិរញ្ញវត្ថុទី១នៃនាយកដ្ឋានអធិការហិរញ្ញវត្ថុ

១០-លោក សួន សុខរើន មន្ត្រីការិយាល័យសហប្រតិបត្តិការពហុភាគីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១១-លោកស្រី ញាន កន្និកា មន្ត្រីការិយាល័យនីតិកម្មនៃនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍
១២-លោក ញ៉ែត ទូ ប្រធានការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តកំពត
១៣-លោក សុខ សីហា មន្ត្រីការិយាល័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តស្វាយរៀង
១៤-លោកស្រី ជា ណារ៉ាត់ មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តរតនគិរី
១៥-លោក សឹម ចាក់ដេត មន្ត្រីការិយាល័យទូរគមនាគមន៍នៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តឧត្តរមានជ័យ

| | | | |
|---|---|---|---|
| ១៦-កញ្ញា | ផាវ | ចាន់អេង | ប្រធានការិយាល័យ |
| ១៧-លោក | ភួង | តេរ៉ូ | អនុប្រធានការិយាល័យ |
| ១៨-លោក | ប្រាក់ | សុវណ្ណនី | អនុប្រធានការិយាល័យ |
| ១៨-លោក | ចាប | ឧត្តម | អនុប្រធានការិយាល័យ |
| ២០-លោក | គឹម | ចាន់ឌី | អនុប្រធានការិយាល័យ |
| ២១-លោក | ជា | សុវណ្ណរង្សា | និយោជិត |
| ២២-លោក | ថាច់ | សំណព្វ | និយោជិត |
| ២៣-លោកស្រី | ឌុក | សានិត្យ | និយោជិត |
| ២៤-លោកស្រី | ឆើយ | សុដាវី | និយោជិត |
| ២៥-កញ្ញា | ឡុង | សូនីឡែន | និយោជិត |
| ២៦-លោក | ឈាស់ | នួន | និយោជិត |
| ២៧-លោក | គឹម | ចិន្តា | និយោជិត |
| ២៨-លោក | ឡោ | សុខសិរី | និយោជិត |
| ២៩-កញ្ញា | ទីវ | ដារ៉ាវីត | និយោជិត |
| ៣០-លោក | ភ៉ន់ | សុខខឿន | និយោជិត |
| ៣១-លោក | អ៊ុក | ពិសិដ្ឋ | និយោជិត |
| ៣២-កញ្ញា | ជា | វលក្ខ | និយោជិត |
| ៣៣-លោក | សរ | ពុទ្ធីរ៉ា | និយោជិត |
| ៣៤-លោក | គង់ | សុខហេង | និយោជិត |
| ៣៥-លោក | ខៀវ | ភារ៉ា | និយោជិត |
| ៣៦-លោក | គង់ | វុទ្ធី | និយោជិត |
| ៣៧-លោក | ផន | យ៉ា | និយោជិត |
| ៣៨-លោក | វង់ | សាភន | និយោជិត |
| ៣៩-លោក | រដ្ឋ | គីរ៉ា | និយោជិត |
| ៤០-កញ្ញា | ជូ | សុភា | និយោជិត |
| ៤១-កញ្ញា | ស | សុភា | និយោជិត |
| ៤២-លោក | តិប | វិចិត្រ | និយោជិត |
| ៤៣-លោក | ខ្លូវ | សារ៉ាដានី | និយោជិត |
| ៤៤-លោក | រ៉េត | រង្សា | និយោជិត |
| ៤៥-លោក | សុក | ស៊ុយ | និយោជិត |
| ៤៦-លោក | ស៊ិន | ស៊ីណា | និយោជិត |
| ៤៧-លោកស្រី | សុខ | មុំ | និយោជិត |
| ៤៨-លោកស្រី | ហ៊ុត | ធីតា | និយោជិត |
| ៤៩-លោកស្រី | ធី | អ៊ិ | និយោជិត |
| ៥០-លោកស្រី | ទេព | សាលីន | និយោជិត |

| | | | |
|---|---|---|---|
| ៥១-លោក | អេង | លន | និយោជិត |
| ៥២-លោក | ឡាច | សុលីម | និយោជិត |
| ៥៣-លោក | អាត់ | វ៉េត | និយោជិត |
| ៥៤-លោក | ហែម | ស្រ៊ុន | និយោជិត |
| ៥៥-លោក | ចាន់ | សាក់ | និយោជិត |
| ៥៦-លោក | ងួន | សីហា | និយោជិត |
| ៥៧-លោក | លី | ប៊ុនថេង | និយោជិត |
| ៥៨-លោក | សុខ | សូល័ក្ខ | និយោជិត |
| ៥៩-លោក | ទូត | ចុប | និយោជិត |
| ៦០-លោកស្រី | ប៉ាល់ | ប៉ូលីន | និយោជិត |
| ៦១-កញ្ញា | គួរ | សម្ផស្ស | និយោជិត |
| ៦២-លោកស្រី | អ៊ិត | ចាន់រិទ្ធ | និយោជិត |
| ៦៣-លោកស្រី | ណាប់ | ស្រីថាច់ | និយោជិត |

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមាសការងារ** ចំនួន ០៤គ្រឿង ជូនមន្ត្រីរាជការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងការស្តាបនាផ្លូវជាតិលេខ ៥៦(សិរីសោភ័ណ-សំរោង) កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. លោក | **នខ សម្បត្តិវឌ្ឍនា** | មន្ត្រីនាយកដ្ឋានបុគ្គលិក-ធនធានមនុស្ស |
| ២. លោកស្រី | **កៅ ម៉ាលីនដូជាទី** | មន្ត្រីមជ្ឈមណ្ឌលជួសជុល និងថែទាំផ្លូវថ្នល់ |
| ៣.លោកស្រី | **អែម កន្និដ្ឋា** | មន្ត្រីអង្គភាពស្តាបនាផ្លូវថ្នល់ PMU3 |
| ៤. លោកស្រី | **វន សុខម៉ិច** | មន្ត្រីអង្គភាពស្តាបនាផ្លូវថ្នល់ PMU3 |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៣៣៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**_បំពាក់ **មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ** ចំនួន ០៣គ្រឿង ជូនមន្ត្រីរាជការនៃក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០៣រូប ដែលមានស្នាដៃល្អក្នុងការស្តាបនាផ្លូវជាតិលេខ ៥៦(សិរីសោភ័ណ សំរោង) កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១. លោក **ម៉ិច ហេង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃនាយកដ្ឋានផ្លូវទឹក |
| ២. លោក **គង់ សុគិន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃមជ្ឈមណ្ឌលជួសជុល និងថែទាំផ្លូវ-ថ្នល់ |
| ៣. លោក **ធិត សុធី** | មន្ត្រីនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និងវិស្វកម្ម |

**មាត្រា ២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៣៣៦...អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**
**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា១.**-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១៨រូប ដែលបានរួមចំណែកជួយអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា នៅវត្តធម្មិស្សរារាម ស្ថិតក្នុងភូមិទី៣ ឃុំព្រែកអាជី ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

១-ព្រះគ្រូធុរៈភាណកោ **ខេង ឡុងហាន** ប្រធានសង្ឃប្រចាំវត្តធម្មិស្សរារាម
២-លោក **ទ៉ាន់ សំអែល** សប្បុរសជន
៣-លោក **អាត ទ៉ាន់ថា** សប្បុរសជន

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១-លោក **សុន ម៉ៅ** សប្បុរសជន
២-ឧបាសិកា **ខាន់ សាឿន** សប្បុរសជន
៣-លោក **ឡុន លីន** សប្បុរសជន
៤-លោក **ហៀង សុវណ្ណ** សប្បុរសជន
៥-ឧបាសិកា **មួយ ហ្គិច** សប្បុរសជន
៦-លោក **លាវ យូហាន** សប្បុរសជន
៧-ឧបាសក **ព្រឿង ព្រួន** សប្បុរសជន

**គ-មេដាយសិរីវឌ្ឍនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | យ៉ែម | ថុន | អាចារ្យវត្ត |
| ២-លោក | រិន | ចាន់ថុន | សប្បុរសជន |
| ៣-ឧបាសិកា | ខាន់ | ទ៉េត | សប្បុរសជន |
| ៤-លោក | ទេព | ផេព | សប្បុរសជន |
| ៥-លោក | ខៃ | ខែម | សប្បុរសជន |
| ៦-លោក | សែម | ខែម | សប្បុរសជន |
| ៧-លោក | ឡាច | ឡាំ | សប្បុរសជន |
| ៨-លោក | ខាន់ | រ៉ែន | សប្បុរសជន |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៣៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៩ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ និងបានជួយអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា នៅឃុំព្រែកអាជី ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | ជុំន | ចំនួវីរៈ | នាយករដ្ឋបាលសាលាស្រុក |
| ២-លោក | ឡូលាស់ | ម៉ាត់ | សមាជិកក្រុមប្រឹក្សាស្រុក |
| ៣-លោក | នុត | សន | អភិបាលរងស្រុក |
| ៤-លោក | គន | គ្រី | មេឃុំព្រែកអាជី |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-លោក | ឡឹក | វណ្ណី | មេប៉ុស្តិ៍ព្រែកអាជី |
| ២-លោក | គា | គន | ក្រុមប្រឹក្សាឃុំព្រែកអាជី |
| ៣-លោក | ជា | ហេង | ក្រុមប្រឹក្សាឃុំព្រែកអាជី |
| ៤-លោក | អ៊ីវ | លីហួរ | ក្រុមប្រឹក្សាឃុំព្រែកអាជី |

**គ-មេដាយសំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| -លោកស្រី | ឌុយ | ម៉ិនថា | ស្មៀនឃុំព្រែកអាជី |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៣៨ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយសុវត្ថារា**
**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ម៉ាន់ សុះ** មេឃុំកំពង់ទ្រាស ដែលមានស្នាដៃល្អក្នុងការសម្របសម្រួលការងារផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងសុខភាព នៅសហគមន៍ជនបទ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ ២០១៦
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា　　　　ជាតិ　សាសនា　ព្រះមហាក្សត្រ

លេខ: ៣៣៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងការសម្របសម្រួលការងារផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងសុខភាព នៅសហគមន៍ជនបទ ទទួលបានលទ្ធផលល្អ កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- លោកស្រី **សូ សុវណ្ណារ៉ា**　　អភិបាលរងស្រុកបន្ទាយមាស ខេត្តកំពត

២- លោកស្រី **ហែម សារឿន**　　ក្រុមប្រឹក្សាឃុំសម្បត្តិមានជ័យ ស្រុករមាសហែក ខេត្តស្វាយរៀង

៣- លោកស្រី **សៅ សុគី**　　ក្រុមប្រឹក្សាឃុំថ្មី ស្រុកគូលែន ខេត្តពោធិ៍សាត់

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មករា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤០ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.** បំពាក់ មេដាយសិរីវឌ្ឍស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន២៤រូប ដែលមានស្នាដៃល្អក្នុងការចូលរួមចំណែកជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តអង្គនារាម ហៅ វត្តស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | វ៉េង | វណ្ណៈ | សប្បុរសជន |
| ២-លោក | រាជ | សុវណ្ណ | សប្បុរសជន |
| ៣-ឧបាសក | សាន | សុន | អាចារ្យវត្ត |
| ៤-ឧបាសក | ហ៊ិន | ផុន | អាចារ្យវត្ត |
| ៥-ឧបាសក | ជាប | ហេន | អាចារ្យវត្ត |
| ៦-ឧបាសក | ស៊ីន | ស៊ីម | អាចារ្យវត្ត |
| ៧-ឧបាសក | អ៊ូ | នន់ | អាចារ្យវត្ត |
| ៨-ឧបាសក | ឈួន | ជាត | គណៈកម្មការវត្ត |
| ៩-ឧបាសក | ឌុច | ស្រេង | គណៈកម្មការវត្ត |
| ១០-ឧបាសក | ប៊ិច | ម៉ៅ | គណៈកម្មការវត្ត |
| ១១-ឧបាសក | ហ៊ិន | ធឿន | គណៈកម្មការវត្ត |
| ១២-ឧបាសក | ទុយ | ថុន | គណៈកម្មការវត្ត |
| ១៣-ឧបាសក | សុខ | ឆុន | គណៈកម្មការវត្ត |
| ១៤-ឧបាសក | សួន | សម្បត្តិ | គណៈកម្មការវត្ត |

| | | | |
|---|---|---|---|
| ១៥-ឧបាសិកា | ឌួត | យ៉ុន | គណៈកម្មការវត្ត |
| ១៦-ឧបាសិកា | ហ៊ុន | គង់ | គណៈកម្មការវត្ត |
| ១៧-ឧបាសិកា | ហយ | ញ៉ី | គណៈកម្មការវត្ត |
| ១៨-ឧបាសិកា | ហុង | អ៊ីម | គណៈកម្មការវត្ត |
| ១៩-ឧបាសិកា | គិន | នៅ | គណៈកម្មការវត្ត |
| ២០-ឧបាសិកា | ម៉ង់ | សាន | គណៈកម្មការវត្ត |
| ២១-ឧបាសក | ចាន់ | ខ្មៅស្រី | គណៈកម្មការវត្ត |
| ២២-ឧបាសិកា | ជៀប | ហឿន | គណៈកម្មការវត្ត |
| ២៣-ឧបាសក | ហ៊ុល | ចន្ណារិន | គណៈកម្មការវត្ត |
| ២៤-ឧបាសិកា | ឌូច | អុន | គណៈកម្មការវត្ត |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៤១...អនក្រ.ថក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១..**បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៩រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមចំណែកជួយកសាងសមិទ្ធផលនានា នៅឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | គង់ | សីហុង | អធិការរងស្រុក |
| ២-លោកស្រី | ហែម | យ៉ាន | មណ្ឌលសុខភាព |

**ខ-មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-លោក | ហេង | សុធី | មន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ២-លោកស្រី | យន | សុវណ្ណារីយ៉ៃ | មន្ត្រីកិច្ចការនារីស្រុក |
| ៣-លោកស្រី | ថុន | ចាន់ធី | មន្ត្រីសាលាស្រុក |
| ៤-លោក | ឡុង | សារិន | អធិការរងស្រុក |
| ៥-លោក | ជា | ម៉ិនពៅ | មេឃុំជីរោទិ៍ទី២ |
| ៦-លោក | អាន | លីមហាន | សមាជិកក្រុមប្រឹក្សាឃុំ |
| ៧-លោកស្រី | លី | សាវ៉ាង | សមាជិកក្រុមប្រឹក្សាឃុំ |
| ៨-លោក | ហុក | ម៉ិនហេង | សមាជិកក្រុមប្រឹក្សាឃុំ |
| ៩-លោក | ខៀវ | សំអឿ | សមាជិកក្រុមប្រឹក្សាឃុំ |
| ១០-លោក | ម៉ៅញ | ហ៊ន់ | សមាជិកក្រុមប្រឹក្សាឃុំ |
| ១១-លោក | សាន | ស្រស់ | នាយកអនុវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន |

**គ-មេជាយសំរឹទ្ធភារខារ**

| | | | |
|---|---|---|---|
| ១-លោក | ជិន | គីមរុន | ស្មៀនឃុំជីរោទិ៍ទី២ |
| ២-លោក | យ៉េង | សុមេធ | នគរបាលឃុំ |
| ៣-លោក | នៃ | ថុន | មេភូមិស្រែសៀម |
| ៤-លោក | ម៉ាង | ឡឿក | មេភូមិអណ្តូងជា |
| ៥-លោក | យូ | យន់ | មេភូមិឯកភាព |
| ៦-លោក | ប្រាក់ | ឃន | មេភូមិម្រាមទាក |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..៣៤៥..អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ ចំនួន០៩រូប ដែលមានស្នាដៃល្អក្នុងការចូលរួមចំណែកជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តអង្គនារាម ហៅ វត្តស្រែសៀម ឃុំដីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១-ភិក្ខុបញ្ញាបទីបោ | **ជឹម** | **សុវណ្ណរ័ត្ន** | ព្រះគ្រូសូត្រស្តាំ វត្តអង្គនារាម |
| ២-លោក | **ជា** | **សុវណ្ណា** | បុគ្គលិកក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ |
| ៣-លោក | **សេង** | **សុខឿន** | អភិបាលរងស្រុក |
| ៤-លោកស្រី | **ឃាង** | **មករា** | អភិបាលរងស្រុក |
| ៥-លោក | **សុខ** | **សុវណ្ណា** | ធម្មការ និងសាសនាស្រុក |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ម** | **ស៊ុន** | អប់រំ យុវជន និងកីឡាស្រុក |
| ២-លោក | **សេន** | **សារុន** | ទីប្រឹក្សាស្រុក |
| ៣-លោក | **មិន** | **ខុន** | អតីតមេឃុំដីរោទិ៍ ទី២ |
| ៤-លោកស្រី | **ង៉ែត** | **រ៉ាំឌី** | នាយិកាសាលាបឋមសិក្សាអង្គនារាម |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០៣ ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.**_បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមចំណែកជួយកសាងសមិទ្ធផលនានា នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១-លោក | ឈុន | សារ៉ា | សមាជិកក្រុមប្រឹក្សាឃុំ |
| ២-លោក | សុខ | ឆាន | សមាជិកក្រុមប្រឹក្សាឃុំ |
| ៣-លោកស្រី | ផាន់ | ម៉ាច | សមាជិកក្រុមប្រឹក្សាឃុំ |
| ៤-លោកស្រី | ថូ | ញ៉ី | សមាជិកក្រុមប្រឹក្សាឃុំ |

**ខ-មេដាយសំរិទ្ធការងារ**

| | | | |
|---|---|---|---|
| ១-លោក | ភូត | ផល | មេភូមិស្រឡប់ |
| ២-លោក | កុល | សេខ | មេភូមិត្រពាំងគូ |
| ៣-លោក | ខ្លូត | ឡាច | មេភូមិខ្នារ |
| ៤-លោកស្រី | លន់ | សុខ | មេភូមិវាលខ្នាច |
| ៥-លោកស្រី | តុខ | គីមអួន | មេភូមិត្រពាំងដុំ |
| ៦-លោក | ហោ | ហាក់ | មេភូមិនិគមក្រោម |

| | | | |
|---|---|---|---|
| ៧-លោក | **ឃឹម** | **សារិន** | មេភូមិប្រយ៉ាប |
| ៨-លោក | **ឃឹម** | **សារ៉ែន** | មេភូមិនិគមលើ |
| ៩-លោក | **ស្រី** | **ឃឹម** | មេភូមិត្រពាំងធំ |
| ១០-លោក | **ឈន់** | **ជន** | មេភូមិអង្គរជ័យ |
| ១១-លោក | **យ៉ាន់** | **ឈន់** | មេភូមិត្របុស្ស |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៣៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.** បំពាក់ មេដាយសំរឹទ្ធស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន៣៥រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តគូសាលា ហៅ វត្តខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | សុខ | អាំ | អាចារ្យវត្ត |
| ២-លោក | ញ៉ាំ | ឃួន | អាចារ្យវត្ត |
| ៣-លោក | យ៉ឹម | អឿន | គណៈកម្មការវត្ត |
| ៤-លោក | រស់ | មេន | គណៈកម្មការវត្ត |
| ៥-លោក | ពុធ | ជុំន | គណៈកម្មការវត្ត |
| ៦-លោក | ស៊ាង | សម្បត្តិ | សប្បុរសជន |
| ៧-អ្នកស្រី | ខន់ | លាងគី | សប្បុរសជន |
| ៨-លោក | ជិ | ចន | សប្បុរសជន |
| ៩-លោក | ស៊ីន | សឿន | សប្បុរសជន |
| ១០-លោក | សាន់ | សាធុច | សប្បុរសជន |
| ១១-អ្នកស្រី | អុច | សីមអេង | សប្បុរសជន |
| ១២-អ្នកស្រី | ជុំន | ថេង | សប្បុរសជន |
| ១៣-លោក | ទឹុង | អ៊ីន់ | សប្បុរសជន |

| | | | |
|---|---|---|---|
| ១៤-លោក | ថោង | ជីន | សប្បុរសជន |
| ១៥-លោក | ភូត | ផុត | សប្បុរសជន |
| ១៦-លោក | តាំង | ទី | សប្បុរសជន |
| ១៧-លោក | អ៊ិត | ហ៊ាប | សប្បុរសជន |
| ១៨-លោក | សំ | យឿង | សប្បុរសជន |
| ១៩-លោក | យ៉ីត | គីមហេង | សប្បុរសជន |
| ២០-លោក | យ៉ឹម | ហៃ | សប្បុរសជន |
| ២១-លោក | តុង | រិន | សប្បុរសជន |
| ២២-លោក | ម៉យ | គីមហេង | សប្បុរសជន |
| ២៣-អ្នកស្រី | ទីន | សាន | សប្បុរសជន |
| ២៤-លោក | ហៃ | ឆេង | សប្បុរសជន |
| ២៥-លោក | យ៉ឹម | ហ៊ុច | សប្បុរសជន |
| ២៦-អ្នកស្រី | យ៉ាន | អាន | សប្បុរសជន |
| ២៧-លោក | ធី | សាន | សប្បុរសជន |
| ២៨-លោក | ជូ | ចក់ | សប្បុរសជន |
| ២៩-លោក | ទុំ | រស់ | សប្បុរសជន |
| ៣០-លោក | ហាយ | ហុង | សប្បុរសជន |
| ៣១-លោក | ស៊ុន | រិន | សប្បុរសជន |
| ៣២-អ្នកស្រី | និត | នាម | សប្បុរសជន |
| ៣៣-លោក | ម៉ម | ចាន់ | សប្បុរសជន |
| ៣៤-លោក | គ្រូឌ | សេង | សប្បុរសជន |
| ៣៥-លោក | ស៊ាង | ស៊ី | សប្បុរសជន |
| ៣៦-លោក | ទ្រី | ឆា | សប្បុរសជន |
| ៣៧-លោក | ម៉ីន | សុខុន | សប្បុរសជន |
| ៣៨-លោក | ស្ងួស | សាឯម | សប្បុរសជន |
| ៣៩-លោក | គុំ | ភីន | សប្បុរសជន |

**មាត្រា២**.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា                    ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខៈ ៣៤៥ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន០៤រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តគូសាលា ហៅវត្តខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១-ភិក្ខុ សីលធារោ ឡុញ ផល្លី        ព្រះគ្រូសូត្រស្ដាំ វត្តគូសាលា

២-ភិក្ខុ ជោតសីលោ អ៊ឹក សារឿង        ព្រះគ្រូសូត្រឆ្វេង វត្តគូសាលា

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១-លោក        មេ ណា        គណៈកម្មការវត្ត

២-លោក        ស៊ាម សុជាតិ        មេឃុំស្រឡប់

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៤៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយមាសការងារ** ជូនលោក **ហេង សន្តិភាព** មន្ត្រីជាន់ខ្ពស់ កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យរបស់អង្គការយូនីសេហ្វប្រចាំកម្ពុជា ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ កន្លងមក ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០១ សរណន

**សារាចរណែនាំ**

**ស្ដីពី**

**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧**

**១. សេចក្ដីផ្ដើម**

មាត្រា ៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ដើម្បីឱ្យក្រសួង ស្ថាប័ននីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៧។ នៅជំហានបន្ទាប់ រាជរដ្ឋាភិបាល នឹងដាក់ចេញសារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ដូចរៀងរាល់ឆ្នាំដែរ ដើម្បីផ្ដល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះ សម្រាប់ជាជំនួយដល់គ្រប់ក្រសួង ស្ថាប័នក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផែនការថវិការយៈពេលបីឆ្នាំរំកិល ដែល ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង ស្ថាប័ន នីមួយៗ ត្រូវរៀបចំនៅដំណាក់កាលដំបូងនៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរ ណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷(១) ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២) បង្កើនវិចារណកម្មអាទិភាពចំណាយ

ឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន, (៣) ធានានិរន្តរភាពនៃការអនុវត្តកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័នដើម្បីសម្រេចគោលបំណងគោលនយោបាយ ដែលបានដាក់ចេញ (៤) ជាមូលដ្ឋានសម្រាប់ពន្យល់ និងបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥) ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់លាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ អំពីភាពច្បាស់លាស់នៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាពអំពីសូចនាករនិងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផល នៃការអនុវត្តកម្មវិធី/យុទ្ធសាស្ត្រអាទិភាព សមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**"។ ក្នុងន័យនេះ ក្រសួង ស្ថាប័នមួយ ត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល និង ថវិកាមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទក្រសួង ស្ថាប័ននោះ។

ទន្ទឹមនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាគន្លឹះមិនអាចខ្វះបាន ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាព និងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិសម្រាប់វិភាជនិងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ *ក្រសួង ស្ថាប័ននីមួយៗ ចាំបាច់ត្រូវជំរុញ និងលើកទឹកចិត្តក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង ឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។* **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យធនធានទាំងអស់ ក៏ដូចជាសកម្មភាពការងារទាំងអស់របស់ក្រសួង ស្ថាប័នខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាការវិភាជថវិកាមានប្រសិទ្ធភាព (ចំសេចក្តីត្រូវការពិតប្រាកដ) និងមានតុល្យភាព ឆ្លើយតបជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី/យុទ្ធសាស្ត្រអាទិភាព ដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

ជារួម ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់ជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ គឺ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២០)** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦។ ថ្វីត្បិតការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានកែលម្អជាលំដាប់ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០០៨ ប៉ុន្តែ គុណភាព និង ប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា មិនទាន់ឈានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាន

នៅឡើយ។ ហេតុនេះ ក្រសួង ស្ថាប័ន ចាំបាច់ត្រូវកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្មារតី និងលទ្ធផលនៃការចរចាថវិកាឆ្នាំ ២០១៦ កន្លងទៅ និងជាពិសេសការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ។ *ជាមួយគ្នានេះ ដើម្បីលើកកម្ពស់គុណភាពផែនការយុទ្ធសាស្ត្រថវិកា ក្រសួង ស្ថាប័ននីមួយៗ ចាំបាច់ត្រូវរៀបចំឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងលើកិច្ចការនេះឱ្យបានច្បាស់លាស់បន្ថែមទៀត អំពីតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងអាចដាក់ចេញជាគោលការណ៍ណែនាំផ្ទៃក្នុងស្តីអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជា គោលការណ៍ផ្ទៃក្នុងសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំផងដែរ ជាពិសេសក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី។*

ស្របតាម **"ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០"** ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗពីការផ្តោតលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង ស្ថាប័នចំនួន ២៥ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ហើយក្រសួង ស្ថាប័នចំនួន ១១ បន្ថែមទៀត ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០១៧។ ក្រសួង ស្ថាប័នទាំងនោះ រួមមាន÷

- ក្រសួង ស្ថាប័នចំនួន ២៥ និងមន្ទីរជំនាញរាជធានីខេត្តពាក់ព័ន្ធ ដែលត្រូវបានអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ចាប់ពីឆ្នាំ២០១៦ រួមមាន÷ ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់, ក្រសួងយុត្តិធម៌, តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា, និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- ក្រសួង ស្ថាប័នថ្មីចំនួន ១១ និងមន្ទីរជំនាញរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ចាប់ពីឆ្នាំ២០១៧ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៦ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ រួមមាន÷ ក្រសួងព្រះបរមរាជវាំង, ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងរ៉ែនិងថាមពល, ក្រសួង

ធម្មការ និងសាសនា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ក្រសួងផែនការ និងក្រសួងមុខងារសាធារណៈ។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកា និងលើការអនុវត្តថវិកា នឹងត្រូវផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្រសួង ស្ថាប័នសាមី ចំណែកឯសិទ្ធិអំណាចនៃការទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តថវិកាផ្ទៃក្នុងក្រសួង ស្ថាប័ននីមួយៗ ក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីអគ្គនាយកដ្ឋាន/នាយកដ្ឋានហិរញ្ញវត្ថុ/គណនេយ្យរបស់ក្រសួង ស្ថាប័ន ទៅអង្គភាពថវិកាផ្ទៃក្នុងក្រសួង ស្ថាប័ន។ ក្នុងន័យនេះ គ្រប់ក្រសួង ស្ថាប័ន កាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ក្នុងបរិការណ៍នេះ ដើម្បីជួយឱ្យក្រសួង ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧-២០១៩ ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

## ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ មានតួនាទីផ្តល់ជាទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្អែកគោលនយោបាយ ដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះ បង្កើតបានជាលំហរថវិការួមសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាចកំណត់ទិសដៅការងាររយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនេះ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្អែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការ ពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។

ដោយផ្អែកលើមូលដ្ឋាននៃ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

### ២.១. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្អែកលើចលនការកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជានៃឆ្នាំកន្លងមក និងភាពនៅតែល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើកដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៦ ត្រូវបាន

ព្យាករថា អាចសម្រេចបានក្នុងរង្វង់ ៧,១% លើសបន្តិចពីការប៉ាន់ស្មានដែលបានដាក់ក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។ ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៧ វិញ តាមការព្យាករបឋមអាចនឹងសម្រេចបានក្នុងរង្វង់ ៦,៩%។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ០,១៤% កំណើនវិស័យឧស្សាហកម្មប្រមាណ ១០,៩% ដែលក្នុងនោះ វិស័យវាយនភណ្ឌអាចសម្រេចកំណើនប្រមាណ ៩,៨%, កំណើនវិស័យសំណង់ប្រមាណ ១២,៤% និងកំណើនវិស័យសេវាកម្មប្រមាណ ៦,៨%។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ នៅឆ្នាំ ២០១៦ តាមការព្យាករ នឹងស្ថិតក្នុងកម្រិត ១,៩% គឺទាបជាងការព្យាករ ដែលបានដាក់នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ប៉ុន្តែ អាចនឹងកើនឡើងដល់ ៣,៣% វិញ នៅឆ្នាំ ២០១៧។ អត្រាប្ដូរប្រាក់នៅឆ្នាំ ២០១៦ ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានតម្លៃជាមធ្យម ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក គឺដូចគ្នានឹងការព្យាករក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។ តាមការព្យាករ នៅឆ្នាំ ២០១៧ អត្រាប្ដូរប្រាក់ជាមធ្យមប្រចាំឆ្នាំ នឹងនៅតែមានតម្លៃ ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន ជាពិសេសការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប។

ឱនភាពគណនីចរន្តនៅឆ្នាំ ២០១៦ តាមការប៉ាន់ស្មាននឹងមានកម្រិត ៩,១% នៃផ.ស.ស គឺកាន់តែប្រសើរបើធៀបនឹងឆ្នាំ ២០១៥ ដែលមានកម្រិត ៩,៣% នៃ ផ.ស.ស។ ទន្ទឹមនេះ តាមការព្យាករឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះទៀតមកត្រឹម ៨,៥% នៃផ.ស.ស នៅឆ្នាំ ២០១៧។ និន្នាការនៃការធ្លាក់ចុះ ឱនភាពគណនីចរន្តដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្ដើមមានមូលដ្ឋានផលិតនៅក្នុងស្រុក ជំនួសការនាំចូលជាបណ្ដើរៗ។ នៅឆ្នាំ ២០១៦ ទុនបម្រុងនឹងមានទំហំ ៥ ៤៥៩ លានដុល្លារអាមេរិក និងអាចកើនឡើងដល់ ៥ ៩០៥ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៧ ដែលធានាបានប្រមាណជាង ៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

**២.២ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

ដើម្បីសម្រេចបានតាមគោលដៅក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៧ ដូចខាងក្រោម÷

- បន្តធានាកំណើនចំណូលចរន្តប្រចាំឆ្នាំបន្ថែម ០,៥ ពិន្ទុភាគរយនៃផ.ស.ស ដើម្បីឈានទៅសម្រេចឱ្យបាន ១៨,២៤% នៃផ.ស.ស នៅឆ្នាំ ២០១៧ ដែលក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិមាន ១៧,១៥% នៃផ.ស.ស និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិមាន ១,០៩% នៃផ.ស.ស។ ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវគ្រោងសម្រេចឱ្យបាន ៨,២៩% នៃផ.ស.ស, ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវគ្រោងសម្រេចឱ្យបាន ៧,៧៤% នៃផ.ស.ស (ក្នុងនោះ ថ្នាក់ជាតិ ៦,៦៩% នៃផ.ស.ស និងថ្នាក់ក្រោមជាតិ ១,០៥% នៃផ.ស.ស) និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,២១% នៃផ.ស.ស។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងប្រទេសសរុបសម្រាប់ឆ្នាំ ២០១៧ ត្រូវគ្រោងសម្រេចឱ្យបាន ១៨,៤១% នៃ ផ.ស.ស។

• ចំណាយសរុបនៅឆ្នាំ ២០១៧ នឹងកំណត់ក្នុងរង្វង់ ២៣,៣០% នៃផ.ស.ស ដែលក្នុងនោះគម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិមាន ២២,២១% នៃផ.ស.ស និងគម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិមាន ១,៨១% នៃផ.ស.ស (ដោយគិតបញ្ចូលទាំងឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៧២% នៃផ.ស.ស)។ ចំណាយចរន្តសរុបត្រូវគ្រោងក្នុងកម្រិត ១៤,៨០% នៃផ.ស.ស ដែលគម្រោងចំណាយបន្ទុកបុគ្គលិកមានប្រមាណ ៥២,៧% នៃចំណាយចរន្តសរុប ឬស្មើប្រមាណ ៧,៨០% នៃផ.ស.ស ដោយផ្តោតអាទិភាពលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ, គិតគូរដល់ការបង្កើនប្រាក់សោធននិវត្តជូននិវត្តជន, ការតម្លើងប្រាក់វិភាជសង្គមសម្រាប់គ្រួសារមន្ត្រីរាជការ និងគិតគូរពីការចូលរួមចំណែករបស់រដ្ឋាភិបាលក្នុងរបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ ចំណាយមិនមែនបុគ្គលិក ត្រូវបានគ្រោងប្រមាណ ៤៧,៣% នៃចំណាយចរន្តសរុប ឬស្មើនឹង ៧%នៃផ.ស.ស។ ចំណាយនេះ នឹងត្រូវត្បិតត្បៀតឱ្យមានប្រសិទ្ធភាពបំផុត និងតម្រង់ទៅលើសកម្មភាពកែទម្រង់ និងការពង្រឹងសេវាសាធារណៈ។ ដោយឡែក ចំណាយវិនិយោគ ត្រូវបានគ្រោងក្នុងកម្រិត ៨,៥% នៃផ.ស.ស (គ្រោងកើន ១៦,១%)។

• ជារួម ចំណាយចរន្តថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៧ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

  ◦ វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ១,៩១% នៃផ.ស.ស និងមានកំណើន ៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦
  ◦ វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៦០% នៃផ.ស.ស និងមានកំណើន ១៤,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦
  ◦ វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៥,៤៤% នៃផ.ស.ស និងមានកំណើន ១១,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦
  ◦ វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ១,៤៥% នៃផ.ស.ស និងមានកំណើន ១០,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៦
  ◦ ទន្ទឹមនេះដែរ ចំណាយមូលធន ត្រូវបានគ្រោងប្រមាណ ៨,៥០% នៃផ.ស.ស ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។

• ឈរលើមូលដ្ឋានគម្រោងក្របខ័ណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៧ គ្រោងសម្រេចបានស្មើនឹងប្រមាណ ៣,៤៤% នៃផ.ស.ស ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយមកត្រឹមប្រមាណ ៤,៨៩% នៃ ផ.ស.ស។ ទំហំតុល្យភាពខាងលើ គឺអាចធានាបាននូវចីរភាពថវិកាដែលជាគន្លឹះរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើន ជាពិសេសបង្កើនលំហថវិកា។ *(ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៥-២០១៩ មានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃសារាចរនេះ)*។

ដើម្បីធានាបាននូវការអនុវត្តតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៦ ការគ្រោងថវិកាឆ្នាំ ២០១៧ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋាន យុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

**ក. ផ្នែកចំណូល**

ដើម្បីបន្តសម្រេចបានគោលដៅដែលបានកំណត់លើការប្រមូលចំណូល រាជរដ្ឋាភិបាលនឹងបន្តផ្តោត ការយកចិត្តទុកដាក់ក្នុងការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈ ការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំង សម្រាប់រយៈពេលខ្លី និងមធ្យម ស្របតាម **យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ក្នុងគោលដៅបង្កើនប្រសិទ្ធភាពក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែក មិនមែនសារពើពន្ធ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តប្រឹងប្រែងខ្លាំងក្លាជាងមុន ក្នុងការលើកកម្ពស់វប្បធម៌ បង់ពន្ធ តាមរយៈការកែសម្រួល និងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធដល់អ្នកបង់ពន្ធដើម្បីលើកកម្ពស់ អនុលោមភាព, បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ និងការពង្រឹង ការគៀរគរបន្ថែមនូវចំណូលមិនមែនសារពើពន្ធតាមបណ្តាក្រសួង ស្ថាប័ននានា។

**ក.១ ផ្នែកចំណូលពន្ធដារ**

វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៧ រួមមាន÷

- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងអនុវត្តយ៉ាង ម៉ឺងម៉ាត់ នូវវិធានការតឹងទារ (ចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ) ចំពោះអ្នកជំពាក់បំណុលពន្ធធំៗ ដែលមិនតវ៉ា និង មានបំណុលពន្ធថ្មីៗ។
- បន្តពង្រឹងប្រតិបត្តិការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំង អស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និង ប្រមូលចំណូល,
- បន្តតាមដាន និងជំរុញការអនុវត្តនូវយុទ្ធសាស្ត្រពង្រឹងសេវាអ្នកជាប់ពន្ធ ដែលមានលក្ខណៈគ្រប់ជ្រុង ជ្រោយ ក្នុងនោះរួមមានយន្តការសម្របសម្រួលរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន, កម្មវិធី ផ្តល់សេវាអ្នកជាប់ពន្ធ, ការបណ្តុះបណ្តាលក្រុមមន្ត្រីបង្គោល ដែលមានជំនាញសេវាអ្នកជាប់ពន្ធ និងការផ្សព្វផ្សាយ ។ល។,
- បន្តកែលម្អបន្ថែមលើការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតការយកចិត្តទុកដាក់លើ÷

១. ការជំរុញបន្ថែមលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការប្រកាសពន្ធ និងបង់ប្រាក់ពន្ធ,

២. ពង្រឹងការអនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ០៣ ខែជាប់គ្នា,

៣. បន្តអនុវត្តការកំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា,

- ពង្រឹងបន្ថែមលើប្រសិទ្ធភាព និងគុណភាពនៃការធ្វើសវនកម្មពន្ធដារទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដើម្បីបង្កើនចំណូលពន្ធដារ ដោយផ្តោតសំខាន់លើ÷

១. ជ្រើសរើសសវនករបន្ថែម ឱ្យស្របទៅនឹងកំណើនចំនួនសហគ្រាស និងប្រសិទ្ធភាពការងារ,

២. រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមាន ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាព សវនកម្ម

៣. រៀបចំសារាចរណែនាំស្តីពីការផ្ទេរថ្លៃ (Transfer Pricing),

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានពន្ធដារ តាមដំណាក់កាលនៃការអនុវត្ត, តម្រូវការរបស់អ្នកប្រើប្រាស់ និងតម្រូវការធនធានសម្ភារៈបរិក្ខារ និងរៀបចំផែនការធ្វើលទ្ធកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្អែកទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការងារសេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស និងការធ្វើសវនកម្ម និងការគ្រប់គ្រងបំណុលពន្ធ,
- រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន ១៥០។

**ក.២ ផ្នែកចំណូលគយ និងរដ្ឋាករ**

វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៧ រួមមាន÷

- ពង្រឹងវិធានការបង្ការ, ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់រូបភាព ជាពិសេសលើមុខទំនិញដូចជា ប្រេង, គ្រឿងអេឡិចត្រូនិក, សម្ភារៈសំណង់ និងយានយន្តឱ្យកាន់តែមានប្រសិទ្ធភាព,
- បន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ ដោយយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់សង្គតិភាព និងអនុលោមភាពនៃឯកសារនាំចេញនាំចូល,
- បន្តការងារចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដោយកំណត់ពីវិសាលភាព និងតម្រូវការ ដោយធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- ពិនិត្យលទ្ធភាពក្នុងការពិចារណាបញ្ចប់ការអនុគ្រោះអាករលើតម្លៃបន្ថែម ចំពោះការនាំចូលម៉ូតូ ដោយយកតម្លៃបន្ថែមពេញវិញ ដើម្បីប៉ះប៉ូវលើការបាត់បង់ពន្ធគយជាង ៥០% ពីការនាំចូលម៉ូតូដោយសារមានរោងចក្រតម្លើងនៅក្នុងប្រទេស,

- ពង្រឹងកិច្ចសហការជាមួយសហគមន៍កំពង់ផែ ដោយរៀបចំប្រព័ន្ធប្រកាសគយដោយស្វ័យប្រវត្តិ តាមរយៈការតភ្ជាប់ទៅវិញទៅមកជាមួយប្រព័ន្ធរបស់សហគមន៍កំពង់ផែ,
- បន្តពង្រីក និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយ ឱ្យស្របតាមតម្លៃទិញលក់ពិត ជាពិសេសទំនិញដែលមានវេទយិតភាពលើចំណូល,
- ពិនិត្យលទ្ធភាព និងអនុវត្តការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំពោះមុខទំនិញវេទយិតភាព លើចំណូលពន្ធគយមួយចំនួន និងធ្វើវិមជ្ឈការទៅការិយាល័យគយទូទាំងខេត្ត ក្រុង លើការងារផ្ទៀងផ្ទាត់ តម្លៃគិតពន្ធគយទំនិញមិនមានវេទយិត ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធគយ,
- ធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ហានិភ័យ និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ ដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈ,
- បន្តពង្រឹងយន្តការឆ្លងកាត់ តាមរយៈការពង្រឹងអនុលោមភាពនៃការប្រើប្រាស់ទំនិញក្រោមរបបអនុគ្រោះពន្ធគយ និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំដាក់បណ្តឹងទៅតុលាការ,
- បន្តតាមដាន និងសិក្សាលើការបាត់បង់ចំណូលពន្ធអាករគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត សម្រាប់ជាមូលដ្ឋានក្នុងការកែតម្រូវវិធានការឆ្លើយតបដែលមានស្រាប់ និងបង្កើតឡើងវិធានការចាំបាច់បន្ថែម,
- ពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការដោះស្រាយបញ្ហា ឬកង្វល់នានារបស់ធុរជន,
- បន្តពង្រឹងការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយ និងពង្រឹងសមត្ថភាពមន្ត្រីគយ តាមរយៈការបណ្តុះបណ្តាលជំនាញចាំបាច់ទាំងឡាយ,
- ពង្រឹង និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយឱ្យស្របតាមតម្លៃទំនិញលក់ពិត,
- កំណត់ទិន្នន័យអប្បបរមា ដែលត្រូវមានលើវិក្កយបត្រពាណិជ្ជកម្មក្នុងទម្រង់ជាក់លាក់តាមបទប្បញ្ញត្តិជាធរមាន។

**ក.៣. ផ្នែកចំណូលមិនមែនសារពើពន្ធ**

វិធានការបន្តសម្រាប់អនុវត្ត ក្នុងឆ្នាំ ២០១៧ រួមមាន÷

- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរ តាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ,
- សិក្សា និងវាយតម្លៃលើគោលនយោបាយតម្លៃសម្បទានដីសេដ្ឋកិច្ច, កម្រៃអាជ្ញាប័ណ្ណ, ការបង់កម្រៃនៃការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុន, កម្រៃសួយសារប្រេងកាត និងរ៉ែនានា ដោយពិចារណាទៅលើភាពទាក់ទាញសម្រាប់អ្នកវិនិយោគ និងផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល,

- ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ និងបន្តតាមដានការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីធ្វើការតាមដានវឌ្ឍនភាពក្នុងក្របខ័ណ្ឌអន្តរក្រសួងនៃ "យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨",
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនិងទ្រព្យសម្បត្តិរដ្ឋ តាមរយៈ ការបន្តធ្វើសវនកម្មក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបន្តពង្រឹង និងដាក់ឱ្យអនុវត្តធ្វើបញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ច, ទ្រព្យសម្បត្តិរដ្ឋ រួមបញ្ចូលទាំងទ្រព្យដែលរឹបអូសបានពីបទល្មើសផ្សេងៗ, ការបញ្ចប់គម្រោងនានារបស់ស្ថាប័នថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ, អំណោយរបស់ដៃគូអភិវឌ្ឍ,អង្គការក្រៅរាជរដ្ឋាភិបាល និងសប្បុរសជននានា,
- បន្តពង្រឹងការប្រមូលចំណូលពីអាករស្នាក់នៅ តាមរយៈ ការបន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រួមមានច្រកអន្តរជាតិ និងស្ថានទូត, ស្ថានអគ្គកុងស៊ុល, រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំគ្រាឱ្យបានទៀងទាត់ និងច្បាស់លាស់, និងឈានទៅដល់ការរៀបចំសារាចរណែនាំស្តីពីការគ្រប់គ្រងចំណូលពីអាករស្ថានទូត និងគ្រប់គ្រងសន្លឹកទិដ្ឋាការ ,
- បន្តពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការរៀបចំឡើងវិញ និងអនុវត្តក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើនតម្លាភាព និងប្រសិទ្ធភាពនៃ ការប្រើប្រាស់ប្រភពហិរញ្ញប្បទានក្នុងគោលដៅជំរុញការអភិវឌ្ឍស្ថាប័នគ្រឹះស្ថានសាធារណៈរដ្ឋបាល,
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន,
- ពិនិត្យលទ្ធភាពដាក់អង្គភាពរដ្ឋទាំងឡាយណា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ខ. ផ្នែកចំណាយ

### ខ.១- គោលនយោបាយអាទិភាពផ្នែកចំណាយ

ស្របតាមគោលដៅនៃសូចនាករហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៧-២០១៩ ដូចតទៅ÷

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន,

- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,
- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាជាងមុនក្នុងការប្រមូលចំណូល ដើម្បីបន្តសម្រេចបានតាមទិសដៅដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក,
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀលនៅឆ្នាំ ២០១៨ ដោយផ្សាភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសារធាណៈ ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ក្នុងគោលដៅបង្កើន គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធម៌ និងសង្គតិភាព។ ទន្ទឹមនេះ បន្តការយកចិត្តទុកដាក់បង្កើនប្រាក់សោធននិវត្តជូននិវត្តជន, ការដម្លើងប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ និងគិតគូរពីការរួមចំណែករបស់រាជរដ្ឋាភិបាល ក្នុងរបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល។ ជារួមគោលការណ៍នេះស្ថិតក្នុងការធានាបាននូវចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល,
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ ជាពិសេស ការកែទម្រង់ប្រព័ន្ធកងកម្លាំងប្រដាប់អាវុធ, ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ, ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ,
- បន្តរក្សាអាទិភាព និងវិចារណកម្មចំណាយនៃគោលនយោបាយចំណាយ ដល់វិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព និង ទឹកស្អាតជាដើម ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល និងសេវាសន្តិសុខសង្គម,
- បន្តជំរុញការវិនិយោគ ការពង្រីក ការកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងទៀត ទាំងផ្នែកទន់ និងផ្នែករឹងសម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍជាពិសេស ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី ។ល។,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងបន្តបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញ

ការកែច្នៃសម្រាប់ការនាំចេញផលិតផលឧស្សាហកម្ម និងកសិផល, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព

- បន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ
- ជំរុញការអនុវត្ត "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥**"
- បន្តផ្តល់អាទិភាពលើការវិនិយោគខ្នាតតូច ដែលមានលក្ខណៈអតិពលកម្ម ជាពិសេសធារាសាស្ត្រខ្នាតតូច ក្នុងគោលដៅគាំទ្រដល់ការបង្កើនផលិតភាពក្នុងវិស័យកសិកម្មផង និងគាំទ្រដល់ការលើកកម្ពស់សេដ្ឋកិច្ចជនបទផង,
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយ ដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌,
- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,
- លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ

## ៦.២- ទិដ្ឋភាគការផ្នែកចំណាយ

- បន្តបង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើនប្រសិទ្ធភាពនៃវិភាជថវិកាឱ្យកាន់តែចំទិសដៅ ជាមួយមូលដ្ឋានជាក់លាក់ ពិសេសពង្រឹងសមត្ថភាព ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនិងអង្គភាពថវិកាពីចំនួន ២៥ ក្រសួង ស្ថាប័ន ក្នុងឆ្នាំ ២០១៦ ឱ្យឡើងដល់ ៣៦ ក្រសួង ស្ថាប័ន ក្នុងឆ្នាំ ២០១៧,
- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវនិងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកជាប់កិច្ចសន្យា ក្នុងគោលបំណងផ្ទៀងផ្ទាត់ធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីថ្មី,
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃការអនុវត្តចំណាយថវិកា ទាំងចំណាយចរន្ត (ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិក) និង ទាំងចំណាយមូលធន (ចំណាយវិនិយោគ),
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ,

- បន្តជំរុញការអនុវត្តកញ្ចប់ថវិកាឱ្យដល់អង្គភាពអនុវត្តការងារផ្ទាល់ ទាំងនៅរដ្ឋបាលកណ្តាលនៃក្រសួង ស្ថាប័ន និងនៅតាមបណ្តាមន្ទីរជំនាញរាជធានី ខេត្ត ក្នុងគោលដៅលើកកម្ពស់តម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តចំណាយថវិកា ក៏ដូចជាលើលទ្ធផលការងារ,
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដោយបង្កើនការយកចិត្តទុកដាក់លើមុខចំណាយដែលបង្កើនផលិតភាព និងស្របតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសលើការកែទម្រង់ និងការវិនិយោគទ្រទ្រង់កំណើនសេដ្ឋកិច្ច,
- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ចំណាយថវិកាលើមុខចំណាយទំនិញ និងសេវាមួយចំនួនដូចជា ប្រេងឥន្ធនៈ, អគ្គិសនី, សេវាទូរគមនាគមន៍និងអ៊ិនធើណែត, ការកាត់បន្ថយនូវបេសកកម្មទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិត ហើយមានតម្លៃខ្ពស់,
- ត្បិតត្បៀតលើចំណាយផ្នែកគម្រោងព័ត៌មានវិទ្យា (ICT) ទាំងផ្នែកចំណាយថវិកាចរន្ត ក៏ដូចជាថវិកាមូលធន/វិនិយោគ ព្រោះនៅឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានចំណាយថវិកាយ៉ាងច្រើនរួចហើយលើផ្នែកនេះ។ ប៉ុន្តែ ចាំបាច់ត្រូវពង្រឹងលើការគ្រប់គ្រង ប្រើប្រាស់ និងថែទាំប្រព័ន្ធ សម្ភារៈ និងឧបករណ៍ដែលមានស្រាប់សិន។
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយ ក្នុងគោលបំណងរក្សាឱនភាពថវិកាឱ្យនៅត្រឹមកម្រិតសមរម្យមួយ ដែលមិនប៉ះពាល់និរន្តរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន "**លំហថវិកា**" សម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីប្រធានស័ក្តិនិងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាសនិងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុដែលសម្រេចបាន និងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលជាជំហានទី៣នៃកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២០១៦-២០២០),

- បន្តអនុវត្តនូវរាល់វិធានការគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ក្នុងគោលបំណងបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យ នៅទាប,
- បន្តគាំទ្រដល់សកម្មភាពការងារតាមដាន ត្រួតពិនិត្យ អធិការកិច្ចកម្រិតបច្ចេកទេសផ្នែកបច្ចេកទេស ដែលជាផែនការគាំទ្រដ៏មានសារៈសំខាន់ចំពោះដំណើរការនៃការធ្វើវិមជ្ឈការ ឬវិសហមជ្ឈការសិទ្ធ និងការទទួលខុសលើការគ្រប់គ្រង និងចាត់ចែងអនុវត្តថវិកា។

### ៣. រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោលនយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ដូច្នេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំតាមទម្រង់ដូចខាងក្រោម÷

- **ផ្នែកទី១: អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ត្រូវចាប់ផ្តើមដោយគូសរំលេចអំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៥-២០១៧ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦-២០១៨ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០១៦ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗដែលក្រសួង ស្ថាប័នបានដាក់ចេញដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយរបស់ខ្លួន ដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី១នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

• **ផ្នែកទី២: អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យ និងអន្តរវិស័យ ដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន នីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង ស្ថាប័នខ្លះ អាចត្រួតពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦ របស់ខ្លួនបាន ដើម្បីធានាថា គោលនយោបាយដែលបានកំណត់មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ឆ្លើយតបបានកាន់តែច្បាស់លាស់ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ សូមបញ្ជាក់ផងដែរថា *ក្រសួង ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពីពីរទេ*។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

• **ផ្នែកទី៣: អំពីកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព**

ការរៀបចំកម្មវិធី (ក្រសួង ស្ថាប័ន អនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (ក្រសួង ស្ថាប័នមិនទាន់អនុវត្តថវិកាកម្មវិធី) ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយដែលបានកំណត់ខាងលើ និងត្រូវបញ្ជាក់អំពីគោលបំណងនៃកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង ស្ថាប័នដែលនឹងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំដំបូង ត្រូវបង្កើតឈ្មោះកម្មវិធី ព្រមជាមួយការរៀបរាប់និងពន្យល់អំពីគោលបំណងនៃកម្មវិធីទាំងនោះ ចំពោះក្រសួង ស្ថាប័នដែលបាន និងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវធ្វើការពិនិត្យនិងកែលម្អឈ្មោះកម្មវិធីឱ្យកាន់តែល្អប្រសើរ ដោយឡែកក្រសួងមិនទាន់អនុវត្តថវិកាកម្មវិធី ត្រូវពិនិត្យ និងកែលម្អយុទ្ធសាស្ត្រអាទិភាពឱ្យបានច្បាស់លាស់ ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគិតគូរផងដែរដល់ការចូលរួមអនុវត្តការងារ ដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួល-អាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើម។ សូមបញ្ជាក់ផងដែរថា ***ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពមិនឱ្យលើសពី៥ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធីអាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋានក្រោមឱវាទរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និងចង្កោមសកម្មភាព (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី)

ឬចង្កោមសកម្មភាព អាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិន អនុវត្តថវិកាកម្មវិធី) ព្រមទាំងជាមូលដ្ឋានសម្រាប់ការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រ អាទិភាពទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២។

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុងគ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន ត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា**សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព) ឬ អ្នកគ្រប់គ្រងទៅតាមយុទ្ធសាស្ត្រអាទិភាព និង ចង្កោមសកម្មភាពអាទិភាព សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្ត ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន។ មន្ទីរជំនាញរាជធានី ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី ខេត្ត គឺជាដៃ ឬ ខ្សែបណ្តោយរបស់ក្រសួង នៅតាមរាជធានី ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីឬ យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន។

ក្នុងន័យនេះ **ក្រសួង ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញរបស់ខ្លួននៅរាជធានី ខេត្ត អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយ ឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី ខេត្តរបស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់**។ ជាទូទៅ មន្ទីរជំនាញមួយ អាចមានចង្កោមសកម្មភាព ២ ទៅ ៣ ហើយចង្កោមសកម្មភាពនីមួយៗ ត្រូវស្ថិតនៅក្រោមអនុកម្មវិធីរួមមួយនៃកម្មវិធីមួយ ។ លើកលែងតែក្រសួង ស្ថាប័ន ដែលមានតួនាទីនិងភារកិច្ចច្រើន ហើយការងារនោះភាគច្រើនអនុវត្តនៅថ្នាក់ក្រោមជាតិ ដូចជា ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាល ជាដើម ដែលត្រូវមានអនុកម្មវិធីរួមលើសពី ៣ ដែលជាសេវា ឬការងារគាំទ្រដល់កម្មវិធីលើសពីមួយ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី៣នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

• **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬ លទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវមានជ្រើសរើសសូចនាករ (Indicator) សម្រាប់ជារង្វាស់រង្វល់នៃការវាស់វែងលទ្ធផល ឬ សមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅ (Target) សូចនាករលទ្ធផលដែលចង់សម្រេចបាន សម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែង ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ (Output) និងសូចនាករលទ្ធផលឬ លទ្ធផលចុងក្រោយ (Outcome)។

សូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ឬ យុទ្ធសាស្ត្រអាទិភាព ចង្កោមសកម្មភាពអាទិភាពទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។

រីឯសូចនាករលទ្ធផលឬលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើស សម្រាប់វាស់សមិទ្ធកម្មចុងក្រោយនៃកម្មវិធី អនុកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព ដែលជាលទ្ធផលសម្រេចបានដោយការបូកបញ្ចូលគ្នានូវលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ហេតុនេះ ការកំណត់ និងវាស់វែងលទ្ធផលចុងក្រោយ គឺត្រូវកំណត់យកត្រឹមឆ្នាំ ២០១៨ ស្របតាម **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។

ក្រសួង ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៥ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៦ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករយ៉ាងច្រើនចំនួន៣** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំនិងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណ ឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗនៅក្នុងរយៈពេលមធ្យមនិងវែង (លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តា

ចាំបាច់និងសំខាន់បំផុតគឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមានភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៤នេះទៅតាម តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងផងដែរទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពសម្រាប់រយៈពេលបីឆ្នាំរំកិល ២០១៧-២០១៩។

**ក-ការគ្រោងចំណូល**

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល៣ឆ្នាំ (២០១៧-២០១៩) ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង ប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ តាមរយៈការដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង ស្ថាប័នីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។** នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលដោយកត្តាអត្តនោម័ត គឺជាកម្មវត្ថុនៃការរិតត្បិត ឬលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ (២០១៧-២០១៩) ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៥នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

ទី១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និង ចំណាយមូលធនឬ ហៅថា ចំណាយវិនិយោគ,

ទី២- ការវាយតម្លៃលើសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៦ ដែលក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗកំពុងអនុវត្ត,

ទី៣- ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដោយត្រូវគិតគូរឈេលើទិដ្ឋភាពបី ÷

- គោលនយោបាយ និង សកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ,
- គោលនយោបាយ ឬ សកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ , និង
- គោលនយោបាយថ្មី ។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០១៧-២០១៩ តាមគោលការណ៍នៃការកំណត់ពិដានកញ្ចប់ថវិកា ដូចខាងក្រោម÷

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤) សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៧, ២០១៨ ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៦ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១៦ ដោយតម្លើងបៀវត្សមូលដ្ឋានចំនួន ១២% ក្នុងមួយឆ្នាំ (គិតពីខែមករា ដល់ ធ្នូ) ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។ ចំពោះការតម្លើងប្រាក់បំណាច់មុខងាររបស់មន្ត្រី

រាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ឆ្នាំ ២០១៧ និង ២០១៨ នឹងត្រូវបានផ្តល់ទឹកប្រាក់បន្ថែមគិតពីខែ មេសានៃឆ្នាំនីមួយៗ ដោយផ្អែកលើកម្រិតនៃប្រាក់បំណាច់មុខងារនីមួយៗ ដោយកម្រិតក្រោម ៣០០ ០០០រៀល ក្នុង ១ខែ បន្ថែមចំនួន ១០០ ០០០ រៀល និងបង្កើនរហូតដល់កម្រិតចាប់ពី ៨០០ ០០០រៀល ក្នុង ១ខែ បន្ថែមត្រឹម ៤០ ០០០រៀល ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងចេញគោលការណ៍លម្អិតបន្ថែមសម្រាប់ការបន្ថែមជូនសម្រាប់កម្រិតចន្លោះពី ៣០០ ០០០រៀល ទៅ ៨០០ ០០០រៀល ក្នុងមួយខែ សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនាពេលខាងមុខ។ ដោយឡែក សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៩ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៨ ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។

- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០១៧ ត្រូវគ្រោងស្មើនឹងកម្រិតឥណទានអតិបរមានៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ព្រោះអាទិភាពចំណាយឆ្នាំ ២០១៧ ដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺផ្តោតជាសំខាន់លើការតម្លើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ។ ***ក្នុងន័យនេះ ក៏មិនមែនមានន័យថាកញ្ចប់ថវិកាឆ្នាំ ២០១៧ នឹងទទួលបានស្មើឆ្នាំ ២០១៦ ដោយស្វ័យប្រវត្តិដែរ*** ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ហើយថវិកាដែលបានកាត់ចេញនោះមិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញនោះទេ លុះត្រាតែផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី។ ដោយឡែក សម្រាប់ឆ្នាំ ២០១៨ និង ២០១៩ ការគ្រោងចំណាយចរន្តអាចបង្កើនក្នុងរង្វង់នៃកម្រិតអតិផរណា ធៀបនឹងកញ្ចប់ដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៧ និង ឆ្នាំ ២០១៨។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ និងខ្ពស់ជាងគោលការណ៍ដែលបានចែងនេះ គឺត្រូវផ្តល់ការពន្យល់ និងអំណះអំណាងឱ្យបានត្រឹមត្រូវ ជាក់លាក់ និង ច្បាស់លាស់ ទើបអាចជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាបាន។ ជារួម ***គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្តចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល។***

- **ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ និង

ការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩។

### ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្ត ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និងមានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ គឺជាដំណាក់កាលទី ១ នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង ស្ថាប័ននីមួយៗ មានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការសំខាន់ៗសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ឱ្យបានសមស្រប ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦ របស់ខ្លួន ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។

***គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៧-២០១៩ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៦*** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ដើម្បីសម្រួលដល់ដំណើរការពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននីមួយៗ ***មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមពេលវេលាដែលបានកំណត់ខាងលើ***។ ប្រសិនបើក្រសួង ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកា តាមពេលវេលា

កំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០១៦។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

“ដើម្បីជូនជ្រាប”

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច “ដើម្បីចុះផ្សាយ”

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

“ដើម្បីមុខការ”

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ១៦១........សហវ...ប្រក

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលការិយាល័យមួយចំនួន**
**ក្រោមឱវាទនាយកដ្ឋានថវិកានីយកម្ម និង នាយកដ្ឋានហិរញ្ញកិច្ច**
**នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ ប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh



ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664   Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការមួយ.-**

ប្រការទាំងឡាយ នៃជំពូកទី៤ ស្តីពីនាយកដ្ឋានថវិកានីយកម្ម និងជំពូកទី៥ ស្តីពីនាយកដ្ឋានហិរញ្ញកិច្ច នៃប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកែសម្រួល ដូចតទៅ÷

### ជំពូកទី៤
### នាយកដ្ឋានថវិកានីយកម្ម

**ប្រការ១៩ ថ្មី.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧត្តុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងរ៉ែនិងថាមពល។

**ប្រការ២០ ថ្មី.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, និង ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

### ជំពូកទី៥
### នាយកដ្ឋានហិរញ្ញកិច្ច

**ប្រការ២៩ ថ្មី.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧត្តុនិយម, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, និង ក្រសួងរ៉ែនិងថាមពល។

**ប្រការ៣០ ថ្មី.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, និង ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

**ប្រការពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៨៧០......សហវ.ប្រក.

## ប្រកាស
## ស្តីពី
## ការបង្កើតនិងតែងតាំងក្រុមលទ្ធកម្ម
## របស់អង្គភាពថវិកាថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិការកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាស ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាស ៥៥៨ សហវ.ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ១៨៤២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតនិងតែងតាំងក្រុមលទ្ធកម្មនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដូចខាងក្រោម÷

១. មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រះវិហារ

| | | |
|---|---|---|
| -លោក **ម៉ុម សុទ្ធារ៉ា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រះវិហារ | ជាប្រធាន |
| -លោកស្រី **គង់ ណារ៉ែន** | ប្រធានការិយាល័យថវិកាមន្ទីរជំនាញ | ជាអនុប្រធាន |
| - លោក **សំ សៀម** | អនុប្រធានការិយាល័យលទ្ធកម្មសាធារណៈ | ជាសមាជិក |
| - លោកស្រី **ហ៊ិន រ៉ាធី** | អនុប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក **អៀម រ៉ាមេន** | មន្ត្រីការិយាល័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | ជាសមាជិក |

២. មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តក្រចេះ

| | | |
|---|---|---|
| -លោក **អ៊ុច សុផាន់ណារ្ម** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តក្រចេះ | ជាប្រធាន |
| - លោកស្រី **ឈឹម សុធារី** | អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តក្រចេះ | ជាអនុប្រធាន |
| - លោក **ទូច សុន្លី** | អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តក្រចេះ | ជាសមាជិក |
| - លោកស្រី **ហ៊ុល មណ្ឌល** | អនុប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក **ហ៊្វ លីដា** | មន្ត្រីជំនាញ | ជាសមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៤ សហ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យកន្ទបុប្ផា

## រវាង

## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតម្រូវការចាំបាច់នៃការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

**សម្រេច**

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ដូចមានរាយនាមខាងក្រោម÷

១. លោកជំទាវ **ខួន សុខា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២. ឯកឧត្តម **តែ គុយស៊ាង** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន

៣. ឯកឧត្តម **យឹត ស៊ុនណារ៉ា** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល អនុប្រធាន

៤. ឯកឧត្តម **ចាន់ សុធី** អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៥. លោកជំទាវ **យក់ សម្បត្តិ** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុក្រសួងសុខាភិបាល អនុប្រធាន

៦. លោកជំទាវ **ខ្វិ ចណ្ណាឌីន** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសុខាភិបាល អនុប្រធាន

៧. ឯកឧត្តម **ផាន់ ផល្លា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៨. លោក **ញ៉ឹម ខេមរា** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩. លោក **ហាវ រតនៈ** ប្រធាននាយកដ្ឋានថវិកានីយកម្មក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០. លោក **អ៊ុន មាត្រា** ប្រធាននាយកដ្ឋានធានារ៉ាប់រង និងសោធន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១១. លោក **ម៉ី សំបូរ** ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិកក្រសួងសុខាភិបាល សមាជិក

១២. លោក **សុខ ស្រ៊ុន** ប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល សមាជិក

១៣. លោក **គី សន់ធី** ប្រធានមន្ទីរពេទ្យគន្ធបុប្ផា សមាជិក

១៤. លោក **ឃៃ ចន្ទនា** ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ សមាជិក

១៥. លោក **ស្រី ទុច** អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៦. លោក **ហ៊ិញ ឫទ្ធីពល** អនុប្រធាននាយកដ្ឋានថវិកានីយកម្មក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ២:** ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចតទៅ÷

១-ធ្វើការងារជាមួយលោកវេជ្ជបណ្ឌិត Beat Richner និងមន្ត្រីពាក់ព័ន្ធនៃមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីទទួលព័ត៌មាន និងសិក្សាលើទិដ្ឋភាពហិរញ្ញវត្ថុ,ប្រតិបត្តិការ,សេវាសុខាភិបាល និងនីតិវិធីនៃការគ្រប់គ្រងរបស់មន្ទីរពេទ្យ

២-សិក្សាលើបញ្ហាហិរញ្ញប្បទាននៃមូលនិធិគន្ធបុប្ផា ដើម្បីធានាចីរភាពនៃដំណើរការជាប្រចាំរបស់មន្ទីរពេទ្យនៅថ្ងៃអនាគត ដោយផ្អែកលើគោលការណ៍នៃស្តង់ដារសេវាសមស្រប និងប្រសិទ្ធភាព

៣-រៀបចំយន្តការនៃការគ្រប់គ្រង និងកិច្ចដំណើរការរបស់មន្ទីរពេទ្យ នៅពេលដែលរាជរដ្ឋាភិបាលទទួលយកមន្ទីរពេទ្យនេះមកគ្រប់គ្រងវិញ ដើម្បីឱ្យមន្ទីរពេទ្យនេះក្លាយជាមន្ទីរពេទ្យរដ្ឋដែលមានស្តង់ដារគំរូនាពេលអនាគត។

**ប្រការ៣:** ក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ប្រើប្រាស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

**ប្រការ៤:** សមាជិកក្រុមការងារទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្តមាន។

**ប្រការ៥:** ប្រធានគណៈកម្មាធិការទទួលបន្ទុកលើការងារគ្រប់គ្រងមន្ទីរពេទ្យគន្ធបុប្ផា និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល:**

- ស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១១៥៤ ប្រក

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ០០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ របស់កញ្ញា **ជេត ស៊ីជេត** ប្រធានសមាគមជនជាតិកូរ៉េនៅកម្ពុជា

### សម្រេច

**ប្រការ ១** .-

ត្រូវបានចុះឈ្មោះ **សមាគមជនជាតិកូរ៉េនៅកម្ពុជា** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ៤៤៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ប្រការ ២** .-

**សមាគមជនជាតិកូរ៉េនៅកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើងការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** .-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦
ឧ - រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៉ុល លឹម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ: ២០៧៤ ស.ក

# ប្រកាស
# ស្តីពី
# ការចុះឈ្មោះក្នុងបញ្ជីសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំលេខ ០០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់លោក **ឆុល ទិសាល** ប្រធានសមាគមសហគ្រាសកម្ពុជា ចិន

## សម្រេច

**ប្រការ ១** .-

ត្រូវបានចុះឈ្មោះ **សមាគមសហគ្រាសកម្ពុជា ចិន** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ០៣ ភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

**ប្រការ ២** .-

**សមាគមសហគ្រាសកម្ពុជា ចិន** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើងការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** .-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**ជ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៉ុល លឹម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខៈ ២៧៥៤ ប្រក

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំលេខ ០០១/២០១៦ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ របស់លោក **សូ ណៃ** ប្រធានសមាគមអភិវឌ្ឍន៍ សហគមន៍ខ្មែរ អាស៊ាន

## សម្រេច

**ប្រការ ១** .-

ត្រូវបានចុះឈ្មោះ **សមាគមអភិវឌ្ឍន៍សហគមន៍ខ្មែរ អាស៊ាន** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅភូមិប្រាល ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ។

**ប្រការ ២** .-

**សមាគមអភិវឌ្ឍន៍សហគមន៍ខ្មែរ អាស៊ាន** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** .-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពត ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១៦

ឧ - រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ប៉ុល លឹម

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០២៥ស.ស.រ.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- យោងតាមការចាំបាច់របស់ក្រសួង

## ស ម្រេ ច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ាឬក្រុមបាតុករ **ពាក់ព័ន្ធនឹងបញ្ហាដីធ្លី** ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **លឹម ទាន់** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម **ទេព ធន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម **ឡោ ជាឌុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ៤-ឯកឧត្តម **ហាច្ស សុតសំភារ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់និងជាអគ្គលេខាធិការរងនៃ គ.អ.ឆ.ក | សមាជិក |
| ៥-លោក **សេខ ឡុត** | អគ្គនាយករដ្ឋបាលស្តីទី | សមាជិក |
| ៦-លោក **ឌុឌ្សី ចណ្ណារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ | សមាជិករបចិផ្លេយ៍ |
| ៧-លោក **ភុសល សុពិនគ្ស** | ប្រធាននាយកដ្ឋាននីតកម្ម | សមាជិក |



អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax : 023 215 279 / (855-23) 215 660 / 023 217 031 គេហទំព័រ www.mlmupc.gov.kh /

| | | |
|---|---|---|
| ៨-លោក ឡាយ ផល្លឹម | ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ | សមាជិក |
| ៩-លោក ចេង ស្រុង | ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល | សមាជិក |
| ១០-លោក សយ ឃោសាភា | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិក |
| ១១-លោក អេ ម៉ិនធឿន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគនិងទំនាក់ទំនងអន្តរជាតិ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ | លេខាធិការ |

**ប្រការ ២.**_

ក្រុមការងារមានភារកិច្ច ៖

១- ទទួលជួបក្រុមអ្នកតវ៉ា ឬក្រុមបាតុករ។

២- ទទួលញត្តិនិងឯកសារពាក់ព័ន្ធនានាពីក្រុមអ្នកតវ៉ា ឬក្រុមបាតុករ ។

៣- សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករ។

៤- ស្នើវិធានការដោះស្រាយដើម្បីសុំការសម្រេចពីក្រសួង។

៥- ទំនាក់ទំនងជាមួយក្រុមអ្នកតវ៉ាឬក្រុមបាតុករដើម្បីទទួលបានព័ត៌មានបន្ថែម និងជូនដំណឹងអំពីដំណោះស្រាយ។

៦- តាមដានការអនុវត្តវិធានការក្នុងការដោះស្រាយរហូតដល់ករណីវិវាទត្រូវបានបញ្ចប់ជាស្ថាពរ និងធ្វើរបាយការណ៍ជូនក្រសួងអំពីវឌ្ឍនភាពនៃការដោះស្រាយជាជំហានៗ។

៧- ធ្វើរបាយការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួង។

**ប្រការ ៣.**_

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.**_

ក្រុមការងារអាចប្រើប្រាស់មន្ត្រីក្រោមឱវាទឲ្យជួយការងារតាមការចាំបាច់។

**ប្រការ ៥.**_

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ០២កើត ខែចេត្រ ឆ្នាំមមែ ព.ស. ២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា គ.ស. ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣៤៤៣...ឧសក.ប្រក.១៥

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ របស់ក្រុមហ៊ុន យ៉ាង លីង ស្រេដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

## <u>ស ម្រេ ច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាង លីង ស្រេដ (YAN LING THREAD CO., LTD.) តំណាងដោយ លោកស្រី ZHANG YAN LING បង្កើតរោងចក្រ ខារអំបោះ ដែលមានទីតាំងស្ថិតនៅ ភូមិមិល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| អំបោះដេរ | ១៣១១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រខារអំបោះ យ៉ាង លីង ស្រេដ"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ៩៦៣ ឧថ.កឧ.ប្រក. ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រខារអំបោះ របស់ក្រុមហ៊ុន យ៉ាង លីង ស្រេដ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៧៤៤ ឧសក.ករ.ប្រកក.១៤

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ៨ ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតកេសកាតុង និងផលិតផលផ្សេងៗពីក្រដាស របស់ក្រុមហ៊ុន កំពង់ កន្ទួត មេនូហ្វេកធឺរីង (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន កំពង់ កន្ទួត មេនូហ្វេកធឺរីង (ខេមបូឌា) ខូអិលធីឌី (KOMPONG KANTOUT MANUFACTURING (CAMBODIA) CO., LTD.) តំណាងដោយ លោក YE QINGQUAN បង្កើតរោងចក្រ ផលិតកេសកាតុង និងផលិតផលផ្សេងៗពីក្រដាស ដែលមានទីតាំងស្ថិតនៅ ភូមិត្បូងក្ដី ឃុំបារគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-កេសកាតុង | ១៧០២ |
| ២-ផលិតផលផ្សេងៗពីក្រដាស | ១៧០២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖"រោងចក្រផលិតកេសកាតុង និងផលិតផលផ្សេងៗពីក្រដាស កំពង់ កន្ទួត មេនូហ្វេកធឺរីង (ខេមបូឌា) ខូអិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី៣១ខែ [illegible] ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រផលិតទឹកក្រូច-ទឹកផ្លែឈើ និងទឹកបរិសុទ្ធ របស់ក្រុមហ៊ុន ខ្មែរ ប្រ៊ីវើរី លីមីធីត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥។

## <u>សម្រេច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឱ្យក្រុមហ៊ុន ខ្មែរ ប្រ៊ីវើរី លីមីធីត (KHMER BREWERY LIMITED) តំណាងដោយ លោកស្រី ភាព ហៀក បង្កើតរោងចក្រ ផលិតទឹកក្រូច-ទឹកផ្លែឈើ និងទឹកបរិសុទ្ធ ដែលមានទីតាំងស្ថិតនៅភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ទឹកក្រូច | ១១០៤ |
| ទឹកផ្លែឈើ | ១១០៤ |
| ទឹកបរិសុទ្ធ | ១១០៤ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតទឹកក្រូច-ទឹកផ្លែឈើ និងទឹកបរិសុទ្ធ ខ្មែរ ប្រ៊ីវើរី លីមីធីត"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ដាច់ចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

សាត សាមី

**ចម្លងជូន៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៣៧៤០ ឧសក.អឧ.ព្រសរ.១៤

រាជធានីភ្នំពេញ, ថ្ងៃទី៣១ខែ [illegible] ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ប៉ាស៊ីហ្វិក អឺភើរែល ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥។

## <u>ស ម្រេ ច</u>

<u>ប្រការ១៖</u> អនុញ្ញាតឱ្យក្រុមហ៊ុន ប៉ាស៊ីហ្វិក អឺភើរែល (PACIFIC APPAREL CO., LTD.) តំណាងដោយ លោក **HUANG YONGSHENG** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិក្រពើត្រាំ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ប៉ាស៊ីហ្វិក អឺភើរីល "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ